# ព្រះរាជក្រម

នស/រកម/០២១៦/ ០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥  ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើត ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នៅរដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម.០២១៦.០០៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អូន ព័ន្ធមុនីរ័ត្ន**

**លេខ: ១៥៧ ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

ឯកសារបកប្រែក្រៅផ្លូវការ

# កិច្ចព្រមព្រៀងស្តីពីការបង្កើត
# ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

ប្រទេសជាហត្ថលេខីនៃកិច្ចព្រមព្រៀងបានចុះហត្ថលេខា និងព្រមព្រៀងគ្នា ដូចខាងក្រោម ៖

*ដោយបានពិនិត្យឃើញអំពីសារៈសំខាន់*នៃកិច្ចសហប្រតិបត្តិការក្នុងតំបន់ ក្នុងការរក្សាកំណើនប្រកបដោយនិរន្តរភាព និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច - សង្គមក្នុងតំបន់អាស៊ី និងដែលតាមរយៈនេះ រួមចំណែកដល់ការពង្រឹងសមត្ថភាពរបស់តំបន់ ឆ្លើយតបនឹងវិបត្តិហិរញ្ញវត្ថុ និងវិបត្តិខាងក្រៅផ្សេងទៀត ដែលអាចកើតឡើងជាយថាហេតុក្នុងបរិការណ៍សកលភាវូបនីយកម្ម ។

*ដោយទទួលស្គាល់អំពីសារៈសំខាន់* នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងការពង្រីកការតភ្ជាប់ និងលើកកម្ពស់ការធ្វើសមាហរណកម្មក្នុងតំបន់ ថាជាកត្តាជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាពរបស់ប្រជាជនក្នុងតំបន់អាស៊ី និងជាការរួមចំណែកដល់ចលនការរស់រវើករបស់សេដ្ឋកិច្ចសកលលោក ។

*ដោយដឹងច្បាស់ថា* តម្រូវការរយៈពេលវែងនៃហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់អាស៊ី នឹងត្រូវបានបំពេញបង្គ្រប់ដោយភាពជាដៃគូ រវាងធនាគារអភិវឌ្ឍន៍ពហុភាគីដែលមានស្រាប់ និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (ដែលតាមនេះហៅកាត់ថា "ធនាគារ")។

*ដោយជឿជាក់ថា* ការបង្កើតធនាគារនេះឡើងជាស្ថាប័នហិរញ្ញវត្ថុពហុភាគី ដោយផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ នឹងជួយកៀរគរហិរញ្ញវត្ថុបន្ថែម ទាំងពីខាងក្នុង និងពីខាងក្រៅតំបន់អាស៊ី និងជួយដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទាន ដែលកំពុងប្រឈមដោយប្រទេសនីមួយៗក្នុងតំបន់ ព្រមទាំងរួមចំណែកបន្ថែមដល់ធនាគារអភិវឌ្ឍន៍ពហុភាគីនានាដែលមានស្រាប់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងស្ថិរភាពក្នុងតំបន់អាស៊ី ។

ហេតុដូច្នេះ *បានព្រមព្រៀងគ្នា* បង្កើតធនាគារដែលត្រូវធ្វើប្រតិបត្តិការអនុលោមតាមបទប្បញ្ញត្តិ ដូចខាងក្រោម÷

## ជំពូកទី ១
## គោលបំណង មុខងារ និង សមាជិកភាព

**មាត្រា ១.. គោលបំណង**

១. គោលបំណងរបស់ធនាគារត្រូវរួមមាន÷ (១) ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ជំរុញការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់វិបុលភាពក្នុងតំបន់អាស៊ី តាមរយៈការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និង (២) លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមនានាក្នុងកិច្ចអភិវឌ្ឍ តាមរយៈកិច្ចសហការជិតស្និទ្ធជាមួយស្ថាប័នអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគីផ្សេងទៀត ។

២. នៅក្នុងកិច្ចព្រមព្រៀងនេះ វាក្យស័ព្ទ "អាស៊ី" និង "តំបន់" សំដៅដល់តំបន់តាមចំណាត់ថ្នាក់ភូមិសាស្ត្រ និងធាតុផ្សំផ្សេងទៀត ដែលត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិ ថាជាតំបន់អាស៊ី និងអូសេអានី វៀរលែងតែមានការសម្រេចដោយឡែកផ្សេងពីនេះ ដោយក្រុមប្រឹក្សាទេសាភិបាល ។

**មាត្រា ២.. មុខងារ**

ដើម្បីសម្រេចគោលបំណងរបស់ខ្លួន ធនាគារត្រូវមានមុខងារ ដូចខាងក្រោម÷

(១) ជំរុញការវិនិយោគក្នុងតំបន់ ដោយប្រើប្រាស់មូលធនសាធារណៈ និងឯកជន សម្រាប់បម្រើឱ្យគោលបំណងនៃកិច្ចអភិវឌ្ឍ ជាពិសេស គឺការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ។

(២) ប្រើប្រាស់ធនធានដែលខ្លួនមាន សម្រាប់ហិរញ្ញប្បទានលើកិច្ចអភិវឌ្ឍក្នុងតំបន់ រួមមាន គម្រោង និង កម្មវិធីដែលនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ និងភាពសុខដុមក្នុងតំបន់ទាំងមូល ទន្ទឹមនេះ ត្រូវផ្តល់ការយកចិត្តទុកដាក់ជាពិសេស ចំពោះតម្រូវការរបស់ប្រទេសជាសមាជិកដែលមានការអភិវឌ្ឍតិចតួចក្នុងតំបន់ ។

(៣) លើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគលើគម្រោង សហគ្រាស និងសកម្មភាពនានា ដែលរួមចំណែកដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត និងផ្តល់ឥណទានក្នុងលក្ខខណ្ឌសមស្រប ដើម្បីជួយបំពេញបង្គ្រប់ដល់គម្រោងវិនិយោគឯកជននៅពេលដែលវិស័យឯកជនខ្វះមូលធន និង

(៤) ធ្វើសកម្មភាព និងផ្តល់សេវាផ្សេងទៀតតាមការចាំបាច់ ស្របតាមមុខងាររបស់ខ្លួន ។

**មាត្រា ៣.. សមាជិកភាព**

១. សមាជិកភាពក្នុងធនាគារ ត្រូវបានបើកទូលាយដល់បណ្តាប្រទេសនានា ដែលជាសមាជិករបស់ធនាគារអន្តរជាតិសម្រាប់ការស្តារ និងអភិវឌ្ឍន៍ ឬ ធនាគារអភិវឌ្ឍន៍អាស៊ី ។

ក. សមាជិកក្នុងតំបន់ សំដៅដល់សមាជិកទាំងឡាយដែលត្រូវបានរាយឈ្មោះក្នុងផ្នែក "ក" នៃឧបសម្ព័ន្ធ "ក" និងបណ្តាសមាជិកផ្សេងទៀតដែលត្រូវបានចាត់ចូលក្នុងតំបន់អាស៊ី អនុលោមតាមកថាខណ្ឌទី ២ នៃមាត្រា ១ ។ សមាជិកដទៃផ្សេងទៀត ត្រូវចាត់ទុកជាសមាជិកក្រៅតំបន់ ។

ខ. សមាជិកស្ថាបនិក គឺជាសមាជិកទាំងឡាយដែលត្រូវបានរាយឈ្មោះក្នុងឧបសម្ព័ន្ធ "ក" ហើយដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅត្រឹម ឬ មុនកាលបរិច្ឆេទកំណត់ក្នុងមាត្រា ៥៧ និងបានបំពេញនូវរាល់លក្ខខណ្ឌផ្សេងទៀតនៃសមាជិកភាព មុនកាលាវសានដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥៨ ។

២. សមាជិកនៃធនាគារអន្តរជាតិសម្រាប់ការស្តារនិងអភិវឌ្ឍន៍ និងធនាគារអភិវឌ្ឍន៍អាស៊ី ដែលខកខានមិនបានក្លាយជាសមាជិកស្របតាមមាត្រា ៥៨ អាចសុំចូលជាសមាជិក តាមលក្ខខណ្ឌនានាដែលកំណត់ដោយធនាគារ និងចាំបាច់ត្រូវទទួលបានការបោះឆ្នោតគាំទ្រដោយមតិភាគច្រើនពិសេសរបស់ក្រុមប្រឹក្សាទេសាភិបាល ស្របតាមមាត្រា ២៨ ។

៣. ក្នុងករណីបេក្ខភាពស្នើសុំចូលជាសមាជិក ដែលមិនមែនជារដ្ឋអធិបតេយ្យ ឬ ពុំមានសមត្ថកិច្ចក្នុងការធ្វើទំនាក់ទំនងអន្តរជាតិ ការដាក់ពាក្យស្នើសុំនោះ ចាំបាច់ត្រូវធ្វើឡើងដោយ ឬ ត្រូវទទួលបានការឯកភាពជាមុនពីប្រទេសជាសមាជិកដែលមានសមត្ថកិច្ចលើកិច្ចការអន្តរជាតិនៃបេក្ខភាពស្នើសុំ ។

## ជំពូកទី ២
## ដើមទុន

### មាត្រា ៤.. ដើមទុន

១. ដើមទុនរបស់ធនាគារ ត្រូវមានចំនួន មួយរយពាន់លានដុល្លារអាមេរិក (១០០ ០០០ ០០០ ០០០ ដុល្លារអាមេរិក) បែងចែកជា មួយលានភាគហ៊ុន (១ ០០០ ០០០) ក្នុងមួយភាគហ៊ុនមានតម្លៃ មួយរយពាន់ដុល្លារអាមេរិក (១០០ ០០០ ដុល្លារអាមេរិក) ។ មានតែសមាជិកប៉ុណ្ណោះ ដែលមានសិទ្ធិទិញភាគហ៊ុនទាំងនេះស្របតាមបញ្ញត្តិនៃមាត្រា ៥ ។

២. ភាគហ៊ុនដើមត្រូវបានបែងចែកជា ភាគហ៊ុនត្រូវបង់ និងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ។ ភាគហ៊ុនត្រូវបង់មានតម្លៃសរុបចំនួន ម្ភៃពាន់លានដុល្លារអាមេរិក (២០ ០០០ ០០០ ០០០ ដុល្លារអាមេរិក) និងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់មានតម្លៃសរុបចំនួន ប៉ែតសិបពាន់លានដុល្លារអាមេរិក (៨០ ០០០ ០០០ ០០០ ដុល្លារអាមេរិក) ។

៣. ដើមទុនរបស់ធនាគារ អាចត្រូវបានបង្កើនតាមការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល តាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ស្របតាមមាត្រា ២៨ អាស្រ័យទៅតាមពេលវេលា និងលក្ខខណ្ឌនានា តាមការចាំបាច់ ដោយត្រូវរក្សាសមាមាត្ររវាងភាគហ៊ុនត្រូវបង់ និងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ។

៤. វាក្យស័ព្ទ "ដុល្លារ" និងនិមិត្តសញ្ញា "$" ដែលត្រូវបានប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ សំដៅដល់រូបិយប័ណ្ណជាផ្លូវការរបស់សហរដ្ឋអាមេរិក ។

### មាត្រា ៥.. ការទិញភាគហ៊ុន

១. សមាជិកនីមួយៗ ត្រូវទិញភាគហ៊ុននៃដើមទុនរបស់ធនាគារ ។ ការទិញភាគហ៊ុននៃដើមទុននីមួយៗ ត្រូវរួមមានទាំងភាគហ៊ុនត្រូវបង់ និងទាំងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ តាមសមាមាត្រ ២ ទល់នឹង ៨ ។ ចំនួន

ភាគហ៊ុនដំបូងដែលមានសម្រាប់ឱ្យប្រទេសនីមួយៗទិញដើម្បីអាចក្លាយជាសមាជិកនៃធនាគារស្របតាមមាត្រា ៥៨ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ “ក” ។

២. ចំនួនភាគហ៊ុនដំបូងដែលត្រូវទិញ ដោយប្រទេសដែលបានសុំចូលជាសមាជិកស្របតាមកថាខណ្ឌទី ២ នៃមាត្រា ៣ ត្រូវកំណត់ដោយក្រុមប្រឹក្សាទេសាភិបាល ក្នុងលក្ខខណ្ឌដែលថា ទោះជាក្នុងករណីណាក៏ដោយ ចំនួនភាគហ៊ុនដែលត្រូវបានអនុញ្ញាតឱ្យទិញទាំងនោះ មិនត្រូវបណ្តាលឱ្យថយចុះនូវសមាមាត្រនៃភាគហ៊ុនរបស់សមាជិកក្នុងតំបន់ ដែលបានកំណត់ឱ្យកាន់កាប់ចំនួន ចិតសិបប្រាំភាគរយ (៧៥%) នៃដើមទុនសរុបនោះទេ វៀរលែងតែមានការសម្រេចផ្សេងពីនេះ ដោយក្រុមប្រឹក្សាទេសាភិបាល តាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ស្របតាមមាត្រា ២៨ ។

៣. តាមសំណើរបស់សមាជិកណាមួយ ក្រុមប្រឹក្សាទេសាភិបាលអាចបង្កើនចំនួនភាគហ៊ុនដល់សមាជិកនោះបាន តាមលក្ខខណ្ឌដែលបានកំណត់ដោយក្រុមប្រឹក្សាទេសាភិបាល តាមការសម្រេចដោយមតិភាគច្រើនលើសលប់ស្របតាមមាត្រា ២៨ និងត្រូវគោរពលក្ខខណ្ឌដែលកំណត់ថា ទោះជាក្នុងករណីណាក៏ដោយ ការបង្កើនចំនួនភាគហ៊ុនដល់ប្រទេសណាមួយ មិនត្រូវឱ្យប៉ះពាល់ដល់សមាមាត្រនៃភាគហ៊ុនរបស់សមាជិកក្នុងតំបន់ ដែលបានកំណត់ចំនួន ៧៥% នៃដើមទុនសរុបនោះទេ វៀរលែងតែមានការសម្រេចផ្សេងពីនេះ ដោយក្រុមប្រឹក្សាទេសាភិបាល តាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ស្របតាមមាត្រា ២៨ ។

៤. ក្រុមប្រឹក្សាទេសាភិបាល ត្រូវពិនិត្យមើលឡើងវិញលើដើមទុនរបស់ធនាគារនៅរៀងរាល់ ៥ ឆ្នាំម្តង ។ ក្នុងករណីដែលមានការបង្កើនដើមទុន សមាជិកនីមួយៗត្រូវតែមានឱកាសសមស្រប ក្នុងការទិញភាគហ៊ុនដែលត្រូវបានបង្កើន តាមលក្ខខណ្ឌកំណត់ដោយក្រុមប្រឹក្សាទេសាភិបាល និងទៅតាមសមាមាត្រភាគហ៊ុនដែលសមាជិកនោះមាននៅចុងគ្រា មុនពេលមានការសម្រេចបង្កើនដើមទុន ។ គ្មានសមាជិកណាមួយ អាចត្រូវបានចាប់បង្ខំឱ្យទិញភាគហ៊ុននៃចំណែកណាមួយរបស់ដើមទុន ដែលត្រូវបានបង្កើននោះទេ ។

**មាត្រា ៦.. ការបង់ភាគហ៊ុន**

១. ការបង់ភាគហ៊ុនដំបូងដោយប្រទេសជាហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ ហើយដែលបានក្លាយជាសមាជិកស្របតាមមាត្រា ៥៨ ត្រូវទូទាត់ភាគហ៊ុនត្រូវបង់ជាដំណាក់កាលចំនួន ៥ ឆ្នាំជាប់គ្នា ស្មើនឹង ២០% ក្នុងមួយឆ្នាំ វៀរលែងតែករណីដែលបញ្ញត្តិដោយឡែក តាមកថាខណ្ឌទី ៥ នៃមាត្រានេះ ។ ការបង់ដំណាក់កាលទី ១ ត្រូវធ្វើឡើងដោយសមាជិកក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ឬ នៅមុន ឬ នៅកាលបរិច្ឆេទដែលសមាជិកបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ឬ ការទទួលយក ឬ ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនេះ ស្របតាមកថាខណ្ឌទី ១ នៃមាត្រា ៥៨ ។ ការបង់ដំណាក់កាលទី ២ ត្រូវធ្វើឡើងនៅមួយឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងបានចូលជាធរមាន ។ ការបង់ភាគហ៊ុនទាំង ៣ ដំណាក់កាលចុងក្រោយ ត្រូវធ្វើឡើងរៀងរាល់ឆ្នាំជាបន្តបន្ទាប់ គិតពីកាលបរិច្ឆេទដែលបានបង់លើកមុន ។

២. ការបង់ភាគហ៊ុននៅដំណាក់កាលនីមួយៗ ត្រូវទូទាត់ជារូបិយប័ណ្ណដុល្លារ ឬ រូបិយប័ណ្ណដែលអាចដោះដូរបានផ្សេងទៀត វៀរលែងតែករណីដែលបញ្ញត្តិក្នុងកថាខណ្ឌទី ៥ នៃមាត្រានេះ ។ ធនាគារអាចសម្រេចធ្វើការដោះដូរ

ការទូទាត់នេះទៅជារូបិយប័ណ្ណដុល្លារ នៅពេលណាមួយក៏បាន ។ សិទ្ធិទាំងអស់ រាប់ទាំងសិទ្ធិបោះឆ្នោតផង ដែលសមាជិកទទួលបានដោយសារភាគហ៊ុនត្រូវបង់ និងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ដែលដល់ថ្ងៃត្រូវបង់ប៉ុន្តែមិនបានបង់នឹងត្រូវផ្អាកជាបណ្តោះអាសន្ន រហូតដល់ពេលដែលធនាគារបានទទួលការទូទាត់គ្រប់ចំនួនពីសមាជិក ។

៣. ការបង់ភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ នឹងត្រូវបានធនាគារកោះហៅឱ្យបង់ តែក្នុងកាលៈទេសៈចាំបាច់ដែលធនាគារត្រូវបំពេញកាតព្វកិច្ចនៃការទទួលខុសត្រូវតែប៉ុណ្ណោះ ។ ក្នុងករណីដែលមានការកោះហៅឱ្យបង់បែបនេះ សមាជិកមានជម្រើសបង់ជារូបិយប័ណ្ណដុល្លារ ឬ រូបិយប័ណ្ណដែលតម្រូវសម្រាប់ការអនុវត្តកាតព្វកិច្ចរបស់ធនាគារ ។ ការកោះហៅឱ្យបង់នូវភាគហ៊ុនដែលមិនទាន់បានបង់ ត្រូវធ្វើឡើងក្នុងភាគរយដូចគ្នាចំពោះគ្រប់ភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ទាំងអស់ ។

៤. ធនាគារ ត្រូវកំណត់ទីកន្លែងសម្រាប់ការបង់ភាគហ៊ុនដែលបានចែងក្នុងមាត្រានេះ ប៉ុន្តែ រហូតដល់ពេលមានកិច្ចប្រជុំលើកដំបូងរបស់ក្រុមប្រឹក្សាទេសាភិបាល ការបង់ដំណាក់កាលទី ១ ដូចបានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបង់ជូនរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឋានៈជាស្ថាប័នតម្កល់ដើមទុនរបស់ធនាគារ ។

៥. សមាជិកដែលត្រូវបានចាត់ទុកជាប្រទេសមានការអភិវឌ្ឍតិចតួច សម្រាប់តែគោលដៅនៃកថាខ័ណ្ឌនេះ អាចបង់ភាគហ៊ុនដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ តាមជម្រើសណាមួយ ដូចខាងក្រោម÷

ក. ត្រូវបង់ជាប្រាក់ដុល្លារ ឬ រូបិយប័ណ្ណដែលអាចដោះដូរបានផ្សេងទៀតទាំងស្រុង ដោយអាចបង់ជា ១០ (ដប់) ដំណាក់កាល ដែលក្នុងដំណាក់កាលនីមួយៗ ត្រូវមានចំនួន ១០% ។ ការបង់ដំណាក់កាលទី ១ និងទី ២ ត្រូវធ្វើឡើងអនុលោមតាមកថាខណ្ឌទី ១ ។ ការបង់ដំណាក់កាលទី ៣ រហូតដល់ដំណាក់កាលទី ១០ ត្រូវធ្វើឡើងនាខួបឆ្នាំទី ២ និងខួបនៃឆ្នាំបន្តបន្ទាប់នៃកាលបរិច្ឆេទនៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ ។

ខ. មួយចំណែក ត្រូវបង់ជាប្រាក់ដុល្លារ ឬ រូបិយប័ណ្ណដែលអាចដោះដូរបានផ្សេងទៀត និងមួយចំណែកទៀត ត្រូវបង់ជារូបិយវត្ថុរបស់ប្រទេសជាសមាជិកនោះក្នុងចំនួនមិនលើស ៥០% នៃការបង់ដំណាក់កាលនីមួយៗ ដោយត្រូវអនុលោមតាមកម្មវិធីទូទាត់ ដូចបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។ រាល់ការបង់ដែលកំណត់ក្នុងអនុកថាខណ្ឌ “ខ” នេះ ត្រូវធ្វើឡើងស្របតាមបទប្បញ្ញត្តិ ដូចខាងក្រោម÷

(១) សមាជិក ត្រូវជូនដំណឹងដល់ធនាគារនៅពេលទិញភាគហ៊ុន ស្របតាមកថាខណ្ឌទី ១ នៃមាត្រានេះ អំពីសមាមាត្រនៃការទូទាត់ដែលត្រូវធ្វើឡើងជារូបិយវត្ថុរបស់ប្រទេសខ្លួន ។

(២) នៅរាល់ដំណាក់កាលនីមួយៗនៃការបង់ចំណែកដែលត្រូវទូទាត់ជារូបិយវត្ថុ របស់ប្រទេសជាសមាជិកដូចមានចែងក្នុងកថាខណ្ឌទី ៥ ត្រូវធ្វើឡើងទៅតាមចំនួនដែលបានកំណត់ដោយធនាគារ តាមតម្លៃសមមូលធៀបនឹងរូបិយប័ណ្ណដុល្លារ ។ ចំពោះការបង់នៅដំណាក់កាលដំបូង ត្រូវធ្វើឡើងទៅតាមចំនួនដែលប្រទេសជាសមាជិកយល់ថាសមស្រប ប៉ុន្តែចំនួននេះ ត្រូវជាកម្មវត្ថុនៃការកែតម្រូវឡើងវិញដោយធនាគារ ក្នុងអំឡុងពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង់ ក្នុងករណីដែលធនាគារយល់ថា មានភាពចាំបាច់ត្រូវកែតម្រូវ ដើម្បីបំពេញបង្គ្រប់តាមតម្លៃសមមូលធៀបនឹងរូបិយប័ណ្ណដុល្លារ ។

(៣) នៅពេលធនាគារពិនិត្យឃើញថា អត្រាប្តូរប្រាក់បរទេសមានការប្រែប្រួល ដែលបណ្តាលឱ្យតម្លៃរូបិយវត្ថុរបស់ប្រទេសជាសមាជិកណាមួយធ្លាក់ចុះខ្លាំង សមាជិកនោះត្រូវបង់បង្គ្រប់ឡើងវិញជូនធនាគារ ក្នុងរយៈពេលសមស្របនូវចំនួនចាំបាច់ណាមួយ ដើម្បីរក្សាតម្លៃរូបិយវត្ថុរបស់ខ្លួនដែលតម្កល់ក្នុងធនាគារ ។

(៤) នៅពេលធនាគារពិនិត្យឃើញថា អត្រាប្តូរប្រាក់បរទេសមានការប្រែប្រួល ដែលបណ្តាលឱ្យតម្លៃរូបិយវត្ថុរបស់ប្រទេសជាសមាជិកណាមួយឡើងថ្លៃខ្លាំង ធនាគារត្រូវបង់ជូនសមាជិកនោះវិញ ក្នុងរយៈពេលសមស្របនូវចំនួនចាំបាច់ណាមួយ ដើម្បីកែតម្រូវតម្លៃរូបិយវត្ថុរបស់សមាជិកនោះ ដែលតម្កល់ក្នុងធនាគារ ។

(៥) ធនាគារអាចលះបង់សិទ្ធិរបស់ខ្លួន ក្នុងការទទួលបាននូវការបង់បន្ថែមតាមចំណុច ៣ ខាងលើ ហើយសមាជិកក៏អាចលះបង់សិទ្ធិរបស់ខ្លួនក្នុងការទទួលការបង់បន្ថែមតាមចំណុច ៤ ខាងលើដូចគ្នាដែរ ។

៦. ធនាគារអាចទទួលយកការបង់ភាគហ៊ុនពីសមាជិកណាមួយស្របតាមកថាខណ្ឌទី ៥ (ចំណុច "ខ") នៃមាត្រានេះ ក្រោមទម្រង់ជាលិខិតសន្យាបង់ភាគហ៊ុន សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យដែលបោះផ្សាយដោយរដ្ឋាភិបាលនៃប្រទេសជាសមាជិក ឬ ការតម្កល់ទ្រព្យណាមួយដែលមានតម្លៃស្មើនឹងចំនួនត្រូវបង់ជារូបិយវត្ថុនៃប្រទេសជាសមាជិក ។ ករណីនេះ អាចធ្វើបាន ក្នុងលក្ខខណ្ឌដែលធនាគារមិនទាន់មានតម្រូវការ សម្រាប់ទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ខ្លួនតែប៉ុណ្ណោះ ។ លិខិតសន្យា ឬ សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ដែលបានតម្កល់នេះ ត្រូវមានភាពមិនអាចចរចាបាន គ្មានការប្រាក់ និងត្រូវបង់តាមតម្លៃចារឹក ជូនធនាគារនៅពេលដែលមានតម្រូវការ ។

**មាត្រា ៧.. លក្ខខណ្ឌនៃភាគហ៊ុន**

១. ភាគហ៊ុនដំបូងដែលទិញដោយសមាជិក ត្រូវបោះផ្សាយតាមតម្លៃចារឹក ។ ភាគហ៊ុនក្នុងដំណាក់កាលបន្តបន្ទាប់ ក៏ត្រូវបោះផ្សាយតាមតម្លៃចារឹកដែរ វៀរលែងតែមានការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល តាមមតិភាគច្រើនពិសេស ស្របតាមមាត្រា ២៨ ឱ្យបោះផ្សាយតាមលក្ខខណ្ឌដោយឡែក នៅក្នុងកាលៈទេសៈពិសេសណាមួយ ។

២. ភាគហ៊ុនមិនអាចត្រូវបានភ្ជាប់នូវការសន្យា ឬ ស្ថិតក្រោមការកម្រិតតាមទម្រង់ណាមួយបានឡើយ ហើយអាចត្រូវបានផ្ទេរឱ្យទៅធនាគារតែប៉ុណ្ណោះ ។

៣. សមាជិកមានកាតព្វកិច្ចទទួលខុសត្រូវចំពោះភាគហ៊ុន ត្រឹមកម្រិតនៃចំណែកដែលមិនទាន់បានបង់តែប៉ុណ្ណោះ ។

៤. គ្មានសមាជិកណាមួយ ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ធនាគារ ដោយសារហេតុផលនៃសមាជិកភាពនោះទេ ។

**មាត្រា ៨.. ធនធានធម្មតា**

ក្នុងកិច្ចព្រមព្រៀងនេះ វាក្យស័ព្ទ "ធនធានធម្មតា" របស់ធនាគារសំដៅដល់ ÷

(១) ដើមទុនរបស់ធនាគារ ដែលរួមមានភាគហ៊ុនត្រូវបង់ និងភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ដូចមានចែងក្នុងមាត្រា ៥ ។



៤

(២) ធនធានដែលធនាគារគៀរគរបាន តាមរយៈអំណាចដែលផ្តល់ឱ្យដោយកថាខណ្ឌទី ១ នៃមាត្រា ១៦ ហើយចំពោះភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ត្រូវបង់តាមបញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៦ ។

(៣) ធនធានដែលទទួលបានពីការទូទាត់សងឥណទាន ឬ ការធានាដោយប្រើធនធានដែលមានចែងក្នុងអនុកថាខណ្ឌ ១ និង ២ នៃមាត្រានេះ ឬ ផលចំណូលដែលទទួលបានពីការវិនិយោគទ្រព្យសកម្មរបស់ធនាគារ និងប្រភេទនៃហិរញ្ញប្បទានផ្សេងទៀតដែលត្រូវបានអនុញ្ញាតក្នុងអនុកថាខណ្ឌទី ២ ចំណុច ៦ នៃមាត្រា ១១ ។

(៤) ចំណូលដែលកើតចេញពីការផ្តល់ឥណទាន ដោយប្រើធនធានដូចបានកំណត់ខាងលើ ឬ ពីការធានាដោយប្រើភាគហ៊ុនដែលត្រូវកោះហៅឱ្យបង់ ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៦ និង

(៥) ធនធាន និងចំណូលផ្សេងទៀតដែលធនាគារទទួលបាន ហើយដែលមិនមែនជាប្រភេទធនធានពិសេសរបស់ធនាគារដូចបានកំណត់ក្នុងមាត្រា ១៧ នៃកិច្ចព្រមព្រៀងនេះ ។

## ជំពូកទី ៣
## កិច្ចប្រតិបត្តិការរបស់ធនាគារ

### មាត្រា ៩.. ការប្រើប្រាស់ធនធាន

ធនធាន និងទ្រព្យរបស់ធនាគារ អាចត្រូវបានប្រើប្រាស់សម្រាប់តែការបំពេញមុខងារ និងគោលបំណងរបស់ធនាគារដែលបានបញ្ញត្តិក្នុងមាត្រា ១ និងមាត្រា ២ ប៉ុណ្ណោះ និងត្រូវគោរពតាមគោលការណ៍នៃកិច្ចប្រតិបត្តិការរឹងមាំរបស់ធនាគារ ។

### មាត្រា ១០.. កិច្ចប្រតិបត្តិការធម្មតា និងពិសេស

១. កិច្ចប្រតិបត្តិការរបស់ធនាគារ រួមមាន÷

(១) ប្រតិបត្តិការធម្មតា ដែលត្រូវហិរញ្ញប្បទានពីធនធានធម្មតារបស់ធនាគារដែលមានចែងក្នុងមាត្រា ៨ និង

(២) ប្រតិបត្តិការពិសេស ដែលត្រូវហិរញ្ញប្បទានពីធនធានមូលនិធិពិសេសរបស់ធនាគារដែលមានចែងក្នុងមាត្រា ១៧ ។

កិច្ចប្រតិបត្តិការទាំងពីរប្រភេទនេះ អាចធ្វើហិរញ្ញប្បទានដល់សមាសភាពផ្សេងដាច់ដោយឡែកពីគ្នា ក្រោមគម្រោង ឬ កម្មវិធីតែមួយបាន ។

២. ក្នុងគ្រប់កាលៈទេសៈ ធនធានរបស់ធនាគារត្រូវតែគ្រប់គ្រង ប្រើប្រាស់ ផ្តល់ការសន្យា វិនិយោគ ឬ ចាត់ចែងដាច់ដោយឡែកពីគ្នាទាំងស្រុង រវាងធនធានធម្មតា និងធនធានមូលនិធិពិសេស ។ របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវតែបង្ហាញដាច់ពីគ្នា រវាងប្រតិបត្តិការធម្មតា និងប្រតិបត្តិការពិសេស ។

៣. ក្នុងគ្រប់កាលៈទេសៈ ធនធានធម្មតារបស់ធនាគារ មិនអាចត្រូវបានយកទៅប្រើប្រាស់ ដើម្បីទូទាត់លើការខាតបង់ ឬ កាតព្វកិច្ចណាមួយ ដែលកើតចេញពីប្រតិបត្តិការពិសេស ឬ ប្រតិបត្តិការណាមួយផ្សេងទៀតរបស់ធនាគារដែលត្រូវបានហិរញ្ញប្បទានពីធនធានមូលនិធិពិសេសបានទេ ។

៤. រាល់ការចំណាយដោយផ្ទាល់លើកិច្ចប្រតិបត្តិការធម្មតា ត្រូវទូទាត់ពីធនធានធម្មតារបស់ធនាគារ ។ រាល់ចំណាយដោយផ្ទាល់លើកិច្ចប្រតិបត្តិការពិសេស ត្រូវទូទាត់ពីធនធានមូលនិធិពិសេសរបស់ធនាគារ ។ រាល់ការចំណាយផ្សេងទៀត ត្រូវទូទាត់ទៅតាមការកំណត់របស់ធនាគារ ។

**មាត្រា ១១.. ហិរញ្ញប្បទានិក និង វិធីសាស្ត្រនៃកិច្ចប្រតិបត្តិការ**

១. (ក) ធនាគារអាចផ្តល់ ឬ អាចជួយសម្របសម្រួលលើការផ្តល់ហិរញ្ញប្បទានដល់សមាជិក ទីភ្នាក់ងារ ឬស្ថាប័នថ្នាក់ក្រោមជាតិនៃប្រទេសជាសមាជិក ឬ អង្គភាព ឬ សហគ្រាស ដែលធ្វើប្រតិបត្តិការក្នុងទឹកដីនៃប្រទេសជាសមាជិក ព្រមទាំងទីភ្នាក់ងារ/ស្ថាប័នកម្រិតតំបន់ ឬ អន្តរជាតិ ដែលធ្វើប្រតិបត្តិការលើកិច្ចការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ។

(ខ) ក្នុងកាលៈទេសៈពិសេស ធនាគារអាចផ្តល់ជំនួយដល់ហិរញ្ញប្បទានិកដ៏ទៃផ្សេងទៀត ដែលមិនស្ថិតក្នុងអនុកថាខណ្ឌ "ក" ខាងលើ ប្រសិនបើក្រុមប្រឹក្សាទេសាភិបាល តាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨÷ (១) កំណត់ថា ជំនួយទាំងនោះត្រូវបានរៀបចំដើម្បីបម្រើឱ្យគោលបំណងនិងស្របតាមមុខងាររបស់ធនាគារ ព្រមទាំងជាប្រយោជន៍នៃប្រទេសជាសមាជិក និង (២) កំណត់ច្បាស់លាស់អំពីប្រភេទនៃការផ្តល់ជំនួយដល់ហិរញ្ញប្បទានិកនោះ ស្របតាមបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ។

២. ធនាគារអាចធ្វើប្រតិបត្តិការតាមវិធីសាស្ត្រណាមួយ ដូចខាងក្រោម ÷

(១) ផ្តល់ឥណទានដោយផ្ទាល់ សហហិរញ្ញប្បទាន ឬ ចូលរួមផ្តល់ហិរញ្ញប្បទាន

(២) វិនិយោគលើទ្រព្យមូលធនរបស់ស្ថាប័ន ឬ សហគ្រាសណាមួយ

(៣) ជាអ្នកធានាទី ១ ឬ ទី ២ លើឥណទានទាំងមូល ឬ ផ្នែកខ្លះ ដែលបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច

(៤) ចាត់ចែងប្រើប្រាស់ធនធានមូលនិធិពិសេស ស្របតាមកិច្ចព្រមព្រៀងស្តីពីការប្រើប្រាស់ធនធានមូលនិធិពិសេស

(៥) ផ្តល់ជំនួយបច្ចេកទេស ដែលត្រូវធ្វើឡើងស្របតាមមាត្រា ១៥ ឬ

(៦) ផ្តល់ហិរញ្ញប្បទានតាមវិធីសាស្ត្រដទៃផ្សេងទៀត តាមការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាលដោយមតិភាគច្រើនពិសេស ដូចមានចែងក្នុងមាត្រា ២៨ ។

**មាត្រា ១២.. ដែនកំណត់នៃកិច្ចប្រតិបត្តិការធម្មតា**

១. ក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការធម្មតារបស់ខ្លួន ដូចមានចែងក្នុងអនុកថាខណ្ឌទី ២ ចំណុច (១) ចំណុច (២) ចំណុច (៣) និង ចំណុច (៦) នៃមាត្រា ១១ នៅគ្រប់កាលៈទេសៈ ទឹកប្រាក់សរុបនៃឥណទានដែលបានផ្តល់ ការវិនិយោគលើទ្រព្យសកម្ម ការធានា និងរាល់ទម្រង់នៃការផ្តល់ហិរញ្ញប្បទានផ្សេងទៀតរបស់ធនាគារ មិនត្រូវបានអនុញ្ញាតឱ្យបង្កើនថែមទៀតបានទេ ប្រសិនបើការបង្កើននោះ លើសពីទឹកប្រាក់សរុបនៃ ដើមទុន ទុនបម្រុង និងប្រាក់ចំណេញដែលត្រូវបានរក្សាទុកជាដើមទុនក្នុងធនធានធម្មតារបស់ធនាគារ ។ បើទោះជាត្រូវបានកម្រិតដោយវាក្យខណ្ឌខាងដើមនេះក៏ដោយ ក្រុមប្រឹក្សាទេសាភិបាល ក្រោយពីបានពិនិត្យមើលលើស្ថានភាពហិរញ្ញវត្ថុរបស់

ធនាគារ អាចសម្រេចដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ក្នុងការបង្កើនចំនួនទឹកប្រាក់សរុបខាងលើ រហូតដល់ ២៥០% នៃទឹកប្រាក់សរុបនៃ ដើមទុន ទុនបម្រុង និងប្រាក់ចំណេញដែលត្រូវបានរក្សាទុកជាដើមទុនក្នុងធនធានធម្មតារបស់ធនាគារបាន ។

២. នៅគ្រប់កាលៈទេសៈ ទឹកប្រាក់សរុបនៃដើមទុនរបស់ធនាគារ ដែលបានដកសម្រាប់ធ្វើវិនិយោគ មិនត្រូវលើសពីទឹកប្រាក់សរុបនៃ ដើមទុនដែលបានបង់ និងទុនបម្រុងទេ ។

**មាត្រា ១៣.. គោលការណ៍នៃកិច្ចប្រតិបត្តិការ**

កិច្ចប្រតិបត្តិការរបស់ធនាគារ ត្រូវធ្វើឡើងអនុលោមតាមគោលការណ៍ ដូចខាងក្រោម÷

១. ត្រូវគោរពប្រតិបត្តិតាមគោលការណ៍នៃកិច្ចប្រតិបត្តិការរឹងមាំរបស់ធនាគារ ។

២. ប្រតិបត្តិការរបស់ធនាគារ ត្រូវផ្តល់អាទិភាពដល់ការធ្វើហិរញ្ញប្បទានលើគម្រោង ឬ កម្មវិធីវិនិយោគជាក់លាក់ ការវិនិយោគលើទ្រព្យមូលធន និងការផ្តល់ជំនួយបច្ចេកទេស អនុលោមតាមមាត្រា ១៥ ។

៣. ធនាគារមិនត្រូវផ្តល់ហិរញ្ញប្បទាន ក្នុងទឹកដីនៃប្រទេសជាសមាជិកណាមួយ ប្រសិនបើសមាជិកនោះ បានបដិសេធមិនទទួលយកហិរញ្ញប្បទាននោះ ។

៤. ធនាគារត្រូវធានាថា រាល់កិច្ចប្រតិបត្តិការនីមួយៗរបស់ខ្លួន ត្រូវបានធ្វើឡើងដោយស្របតាមគោលនយោបាយប្រតិបត្តិការ និងហិរញ្ញវត្ថុរបស់ធនាគារ រាប់ទាំងគោលនយោបាយស្តីពីផលប៉ះពាល់លើបរិស្ថាន និងសង្គម ។

៥. ក្នុងការពិនិត្យលើសំណើសុំហិរញ្ញប្បទាន ធនាគារត្រូវសិក្សាដោយប្រយ័ត្នប្រយែងលើគ្រប់ទិដ្ឋភាព ជាពិសេសលទ្ធភាពរបស់ហិរញ្ញប្បទានិក ក្នុងការទទួលយកហិរញ្ញប្បទានពីធនាគារ ឬ ពីប្រភពផ្សេងទៀត ក្រោមលក្ខខណ្ឌឥណទានដែលធនាគារយល់ថា សមស្របចំពោះហិរញ្ញប្បទានិកនោះ ។

៦. ក្នុងការផ្តល់ ឬ ការធានាហិរញ្ញប្បទានណាមួយ ធនាគារត្រូវយកចិត្តទុកដាក់ពិនិត្យលើលទ្ធភាពរបស់ហិរញ្ញប្បទានិក ឬ អ្នកធានា ប្រសិនបើមាន ក្នុងការបំពេញរាល់កាតព្វកិច្ចរបស់ពួកគេ ដែលមានចែងក្នុងកិច្ចសន្យាហិរញ្ញប្បទាន ។

៧. ក្នុងការផ្តល់ ឬ ការធានាហិរញ្ញប្បទានណាមួយ ធនាគារត្រូវរៀបចំលក្ខខណ្ឌហិរញ្ញវត្ថុដែលមានដូចជា÷ អត្រាការប្រាក់ បន្ទុកសេវាផ្សេងទៀត និងកម្មវិធីសងប្រាក់ដើម ប្រកបដោយភាពប្រយ័ត្នប្រយែង ដោយត្រូវពិនិត្យលើរាល់បញ្ហាប្រឈមហិរញ្ញវត្ថុ និងហានិភ័យពាក់ព័ន្ធទាំងឡាយដែលអាចកើតឡើងចំពោះធនាគារ ។

៨. ធនាគារមិនត្រូវដាក់កំហិតណាមួយចំពោះការធ្វើលទ្ធកម្មទំនិញ និងសេវា ពីប្រភពប្រទេសណាមួយឡើយ ទាំងក្រោមគ្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការធម្មតា ឬ កិច្ចប្រតិបត្តិការពិសេសរបស់ធនាគារ ។

៩. ធនាគារត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាថា រាល់ការប្រើប្រាស់ហិរញ្ញប្បទានដែលបានផ្តល់ ធានា ឬ ចូលរួមដោយធនាគារ ត្រូវធ្វើឡើងសម្រាប់បម្រើឱ្យគោលបំណងនៃហិរញ្ញប្បទានទាំងនោះតែប៉ុណ្ណោះ និងត្រូវអនុវត្តប្រកបដោយភាពសន្សំសំចៃ និងស័ក្តិសិទ្ធិភាព ។

១០. ធនាគារត្រូវយកចិត្តទុកដាក់ក្នុងកម្រិតប្រយ័ត្នប្រយែងខ្ពស់ បង្ការជៀសវាងនូវការប្រើប្រាស់ធនធានរបស់ធនាគារដោយគ្មានភាពសមាមាត្រ ដើម្បីបម្រើផលប្រយោជន៍នៃប្រទេសជាសមាជិកណាមួយ ។

១១. ធនាគារត្រូវធ្វើពិពិធកម្មនៃការវិនិយោគក្នុងកម្រិតសមស្រប ទៅលើទ្រព្យមូលធន ។ ក្នុងការវិនិយោគលើទ្រព្យមូលធន ធនាគារមិនត្រូវចាត់ចែងលើកិច្ចដំណើរការ និងមិនត្រូវទាមទារសិទ្ធិគ្រប់គ្រងលើស្ថាប័ន ឬ សហគ្រាស ដែលធនាគារបានដាក់ទុនវិនិយោគនោះទេ វៀរលែងតែករណីចាំបាច់ ដែលត្រូវធ្វើដើម្បីរក្សាការពារទុនវិនិយោគទាំងនោះតែប៉ុណ្ណោះ ។

**មាត្រា ១៤.. លក្ខខណ្ឌនៃការផ្តល់ហិរញ្ញប្បទាន**

១. កិច្ចសន្យានៃការផ្តល់ហិរញ្ញប្បទាន ការចូលរួមផ្តល់ឥណទាន ឬ ការធានាឥណទាន ត្រូវធ្វើឡើងដោយអនុលោមតាមគោលការណ៍ប្រតិបត្តិការដែលមានចែងក្នុងមាត្រា ១៣ និងបទប្បញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ ព្រមទាំងត្រូវកំណត់អំពីលក្ខខណ្ឌនៃឥណទាន និងការធានាទាំងនោះ ។ ក្នុងការកំណត់លក្ខខណ្ឌទាំងនេះ ធនាគារត្រូវប្រយ័ត្នប្រយែងលើការធានាសុវត្ថិភាពនៃផលចំណូល និងស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន ។

២. ប្រសិនបើហិរញ្ញប្បទានិក ឬ អ្នកទទួលបានការធានា មិនមែនជាសមាជិករបស់ធនាគារទេនោះ ក្នុងករណីចាំបាច់ ធនាគារអាចតម្រូវឱ្យប្រទេសជាសមាជិកដែលនឹងមានគម្រោងពាក់ព័ន្ធត្រូវអនុវត្តក្នុងទឹកដីរបស់ខ្លួន ឬ អាជ្ញាធរសាធារណៈ ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់សមាជិកនោះ ផ្តល់ការធានាលើការទូទាត់សងប្រាក់ដើម ការប្រាក់ និងបន្ទុកចំណាយផ្សេងទៀតនៃឥណទាន ដូចមានចែងក្នុងលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន ឬ ធានា ។

៣. ចំនួនទឹកប្រាក់នៃការនិយោគលើទ្រព្យមូលធននៃស្ថាប័ន ឬ សហគ្រាសណាមួយ មិនត្រូវធ្វើឡើងលើសពីកម្រិតអនុបាតធៀបនឹងទ្រព្យមូលធនរបស់ស្ថាប័ន ឬ សហគ្រាសនោះ ដូចមានចែងក្នុងគោលនយោបាយ ដែលបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សានាយកប្រតិបត្តិ ។

៤. ក្នុងការបំពេញកិច្ចប្រតិបត្តិការរបស់ខ្លួន ធនាគារអាចផ្តល់ហិរញ្ញប្បទានជារូបិយវត្ថុនៃប្រទេសជាហិរញ្ញប្បទានិកបាន ដោយត្រូវគោរពប្រតិបត្តិតាមគោលនយោបាយនៃការកាត់បន្ថយហានិភ័យរូបិយប័ណ្ណឱ្យនៅកម្រិតអប្បបរមា ។

**មាត្រា ១៥.. ជំនួយបច្ចេកទេស**

១. ធនាគារអាចផ្តល់យោបល់ និងជំនួយបច្ចេកទេស ព្រមទាំងជំនួយក្រោមទម្រង់ប្រហាក់ប្រហែលដទៃផ្សេងទៀតបាន ដោយត្រូវធ្វើឡើងស្របតាមគោលបំណង និងមុខងាររបស់ធនាគារ ។

២. ក្នុងករណីដែលចំណាយនៃការផ្តល់សេវាទាំងនេះ មិនអាចទទួលបាននូវការទូទាត់ត្រឡប់មកវិញបាន ធនាគារអាចទូទាត់ចំណាយនេះ ចេញពីប្រភពចំណូលរបស់ធនាគារ ។

## ជំពូកទី ៤

## ធនធានហិរញ្ញវត្ថុរបស់ធនាគារ

**មាត្រា ១៦.. អំណាចទូទៅ**

បន្ថែមលើអំណាចដែលបានចែងក្នុងមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ ធនាគារត្រូវមានអំណាច ដូចខាងក្រោម ÷



ស

១. ធនាគារអាចកៀរគរធនធានតាមរយៈការខ្ចី ឬ តាមមធ្យោបាយផ្សេងទៀត ពីប្រទេសជាសមាជិក ឬ ពីប្រភពផ្សេងទៀត ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។

២. ធនាគារអាចទិញ ឬ លក់មូលប័ត្រ ដែលធនាគារបានបោះផ្សាយ ធានា ឬ វិនិយោគ ។

៣. ធនាគារអាចធានាលើមូលប័ត្រទាំងឡាយ ដែលធនាគារបានវិនិយោគ ដើម្បីជួយសម្រួលដល់ការលក់ចេញមូលប័ត្រទាំងនោះ ។

៤. ធនាគារអាចចុះហត្ថលេខា ឬ ចូលរួមចុះហត្ថលេខាធានាលើមូលប័ត្រ ដែលត្រូវបានបោះផ្សាយដោយស្ថាប័ន ឬ សហគ្រាសណាមួយ ដែលធ្វើសកម្មភាពបម្រើឱ្យគោលដៅស្របគ្នាជាមួយនឹងគោលដៅរបស់ធនាគារ ។

៥. ធនាគារអាចវិនិយោគ ឬ ដាក់ជាប្រាក់បញ្ញើនូវធនធានមួយចំនួនរបស់ខ្លួន ដែលមិនទាន់ត្រូវការចាំបាច់ក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន ។

៦. ធនាគារត្រូវធានាថា រាល់មូលប័ត្រដែលបានបោះផ្សាយ ឬ ធានា ដោយធនាគារ ត្រូវមានខ្លឹមសារបញ្ជាក់ច្បាស់លាស់ថា គ្មានរដ្ឋាភិបាលណាមួយត្រូវជាប់កាតព្វកិច្ចដែលកើតពីមូលប័ត្រទាំងនោះទេ វៀរលែងតែវាជាកាតព្វកិច្ចជាក់លាក់ពិសេសរបស់រដ្ឋាភិបាលណាមួយ ហើយក្នុងករណីបែបនេះ ត្រូវបញ្ជាក់អោយបានច្បាស់លាស់។

៧. ធនាគារអាចបង្កើត និងចាត់ចែងគ្រប់គ្រងលើមូលនិធិ ដែលផ្តល់ហិរញ្ញប្បទានដោយភាគីផ្សេង ក្នុងលក្ខខណ្ឌដែលមូលនិធិទាំងនេះ ត្រូវបានបង្កើតឡើងស្របតាមគោលដៅ និងមុខងាររបស់ធនាគារ និងត្រូវដាក់ឱ្យស្ថិតក្រោមក្របខ័ណ្ឌគ្រប់គ្រងមូលនិធិមួយ ដែលអនុម័តដោយក្រុមប្រឹក្សាទេសាភិបាល ។

៨. ធនាគារអាចបង្កើតបុត្រសម្ព័ន្ធរបស់ខ្លួនបាន ដោយត្រូវរៀបចំឱ្យស្របតាមគោលបំណង និងមុខងាររបស់ធនាគារ តែក្នុងករណីមានការអនុម័តដោយក្រុមប្រឹក្សាទេសាភិបាល តាមការបោះឆ្នោតដោយមតិភាគច្រើនពិសេសស្របតាមមាត្រា ២៨ ។

៩. ធនាគារអាចអនុវត្តអំណាចផ្សេងទៀត ព្រមទាំងអាចបង្កើតវិធាននិងបទប្បញ្ញត្តិនានាតាមការចាំបាច់ សម្រាប់បម្រើឱ្យគោលបំណង និងមុខងាររបស់ធនាគារ ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ១៧.. មូលនិធិពិសេស**

១. ធនាគារអាចទទួលយកមូលនិធិពិសេសទាំងឡាយ ដែលត្រូវបានបង្កើតឡើងស្របតាមគោលបំណង និងមុខងាររបស់ធនាគារ និងត្រូវចាត់ចូលជាធនធានរបស់ធនាគារ ។ រាល់ចំណាយលើការគ្រប់គ្រងមូលនិធិពិសេសត្រូវទូទាត់ចេញពីមូលនិធិពិសេសនេះ ។

២. មូលនិធិពិសេសដែលត្រូវបានទទួលយកដោយធនាគារ ត្រូវប្រើប្រាស់ដោយអនុលោមតាមលក្ខខណ្ឌនានាស្របតាមគោលបំណង និងមុខងាររបស់ធនាគារ និងកិច្ចព្រមព្រៀងពាក់ព័ន្ធនឹងមូលនិធិពិសេសទាំងនោះ ។

៣. ធនាគារត្រូវអនុម័តលើវិធាន និងបទប្បញ្ញត្តិពិសេសដែលចាំបាច់នានា សម្រាប់ការបង្កើត ការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិពិសេសនីមួយៗ ។ វិធាន និងបទប្បញ្ញត្តិទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ វៀរលែងតែបទប្បញ្ញត្តិទាំងឡាយដែលបានបញ្ជាក់ច្បាស់លាស់ថា មានអានុភាពអនុវត្តតែចំពោះកិច្ចប្រតិបត្តិការធម្មតារបស់ធនាគារ ។

៤. វាក្យស័ព្ទ "ធនធានមូលនិធិពិសេស" សំដៅដល់ធនធាននៃមូលនិធិពិសេសណាមួយ ដែលរួមមាន÷

(១) មូលនិធិទាំងឡាយដែលទទួលយកដោយធនាគារ សម្រាប់ដាក់បញ្ចូលទៅក្នុងមូលនិធិពិសេស ។

(២) ចំណូលទទួលបានមកវិញពីការប្រើធនធានមូលនិធិពិសេស សម្រាប់ការផ្តល់ឥណទាន ការធានា និងការវិនិយោគលើទ្រព្យមូលធន ដែលបានចាត់ចែងឡើងស្របតាមវិធាន និងបទប្បញ្ញត្តិរបស់ធនាគារ ស្តីពីការគ្រប់គ្រងធនធានមូលនិធិពិសេស ។

(៣) កម្រៃដែលទទួលបានពីការវិនិយោគដោយប្រើប្រាស់ធនធានមូលនិធិពិសេស និង

(៤) ធនធានផ្សេងទៀត ដែលត្រូវបានដាក់ឱ្យស្ថិតក្រោមការចាត់ចែងរបស់មូលនិធិពិសេសណាមួយ ។

**មាត្រា ១៨.. ការវិភាជ និងបែងចែកចំណូលសុទ្ធ**

១. យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ បន្ទាប់ពីបានវិភាជន៍មួយចំណែកទុកជាទុនបម្រុងរួចមក ក្រុមប្រឹក្សាទេសាភិបាលត្រូវសម្រេចលើការបែងចែកចំណូលសុទ្ធរបស់ធនាគារ សម្រាប់ទុកជាដើមទុន និងគោលបំណងផ្សេងទៀត ហើយប្រសិនបើមានចំណែកនៅសល់ ត្រូវបែងចែកជាភាគលាភជូនសមាជិក ។ ការបែងចែកចំណូលសុទ្ធសម្រាប់គោលបំណងផ្សេងទៀត ត្រូវសម្រេចតាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ស្របតាមមាត្រា ២៨ ។

២. ការបែងចែកចំណូលសុទ្ធជូនសមាជិករបស់ធនាគារ ត្រូវធ្វើឡើងទៅតាមសមាមាត្រនៃចំនួនភាគហ៊ុនរបស់សមាជិកនីមួយៗ ។ បែបបទ និងរូបិយប័ណ្ណនៃការទូទាត់ ត្រូវសម្រេចដោយក្រុមប្រឹក្សាទេសាភិបាល ។

**មាត្រា ១៩.. រូបិយប័ណ្ណ**

១. សមាជិកមិនត្រូវដាក់កំហិតណាមួយពាក់ព័ន្ធនឹងរូបិយប័ណ្ណដែលត្រូវទទួលយក រក្សាទុក ប្រើប្រាស់ ឬ ផ្ទេរដោយធនាគារ ឬ ដោយហិរញ្ញប្បទានិកពីធនាគារ ក្នុងការទូទាត់នៅក្នុងប្រទេសណាមួយឡើយ ។

២. ក្នុងករណីដែលមានភាពចាំបាច់ត្រូវធ្វើការវាយតម្លៃរូបិយប័ណ្ណណាមួយ ឬ កំណត់ថារូបិយប័ណ្ណណាមួយជារូបិយប័ណ្ណដែលអាចដោះដូរបាន ការវាយតម្លៃ ឬ ការកំណត់ទាំងនោះ ត្រូវធ្វើឡើងដោយធនាគារ ។

**មាត្រា ២០.. វិធីសាស្ត្រនៃការទទួលខុសត្រូវរបស់ធនាគារ**

១. ក្នុងកិច្ចប្រតិបត្តិការធម្មតារបស់ធនាគារ ប្រសិនបើកើតមាននូវបំណុលដែលសងមិនទាន់ពេល ឬ មិនអាចទារវិញបាន ដែលធនាគារបានផ្តល់ឥណទាន បានចូលរួមផ្តល់ឥណទាន ឬ បានធានា និងក្នុងករណីដែលខាតបង់ដោយសារការវិនិយោគលើទ្រព្យមូលធនណាមួយ ឬ ប្រភេទនៃការធ្វើហិរញ្ញប្បទានផ្សេងទៀត ដូចមានចែងក្នុងអនុកថាខណ្ឌទី ២ (ចំណុច ៦) នៃមាត្រា ១១ ធនាគារត្រូវចាត់វិធានការដោះស្រាយសមស្របតាមការចាំបាច់ ។ ធនាគារត្រូវរក្សានូវកម្រិតធនធានបម្រុងសមស្រប សម្រាប់ទប់ទល់នូវរាល់ការខាតបង់ដែលអាចកើតមានជាយថាហេតុ ។

២. ការខាតបង់ទាំងឡាយរបស់ធនាគារដែលកើតចេញពីកិច្ចប្រតិបត្តិការធម្មតា ត្រូវទូទាត់ចេញពីប្រភពតាមលំដាប់បន្តបន្ទាប់ ដូចខាងក្រោម÷

(១) ទី ១ ពីធនធានបម្រុងដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ

(២) ទី ២ ពីចំណូលសុទ្ធ

(៣) ទី ៣ ពីទុនត្រៀមបម្រុង និងប្រាក់ចំណេញរក្សាទុកជាដើមទុន

(៤) ទី ៤ ពីដើមទុនត្រូវបង់ និង

(៥) ទី ៥ អាចយកពីចំនួនសមស្របណាមួយពីដើមទុនដែលអាចកោះហៅឱ្យបង់ដែលបានទិញនិងដែលមិនទាន់បានកោះហៅឱ្យបង់ ស្របតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ នៃមាត្រា ៦ ។

## ជំពូកទី ៥
## អភិបាលកិច្ច

**មាត្រា ២១.- រចនាសម្ព័ន្ធ**

ធនាគារត្រូវមានក្រុមប្រឹក្សាទេសាភិបាល ក្រុមប្រឹក្សានាយកប្រតិបត្តិ ប្រធាន ០១ រូប អនុប្រធាន ០១ រូប ឬ ច្រើនរូប ព្រមទាំងមន្ត្រី និងបុគ្គលិកមួយចំនួនទៀត តាមការចាំបាច់ ។

**មាត្រា ២២.- ក្រុមប្រឹក្សាទេសាភិបាល÷ សមាសភាព**

១. សមាជិកនីមួយៗ ត្រូវតែងតាំងទេសាភិបាល ០១ រូប និងទេសាភិបាលជំនួស ០១ រូប សម្រាប់តំណាងក្នុងក្រុមប្រឹក្សាទេសាភិបាល ។ ទេសាភិបាល និងទេសាភិបាលជំនួសនីមួយៗ ត្រូវបំពេញភារកិច្ចជាអ្នកតំណាងរបស់សមាជិកដែលបានតែងតាំងខ្លួន ។ ទេសាភិបាលជំនួសគ្មានសិទ្ធិបោះឆ្នោតទេ វៀរលែងតែករណីទេសាភិបាលអវត្តមាន ។

២. នៅរៀងរាល់កិច្ចប្រជុំប្រចាំឆ្នាំ ក្រុមប្រឹក្សាទេសាភិបាលត្រូវបោះឆ្នោតជ្រើសរើសទេសាភិបាល ០១ រូប ដើម្បីធ្វើជាប្រធានក្រុមប្រឹក្សាទេសាភិបាល ដែលត្រូវបំពេញតួនាទីជាប្រធាននេះ រហូតដល់ពេលមានការបោះឆ្នោតជ្រើសរើសប្រធានបន្ទាប់ ។

៣. ទេសាភិបាល និងទេសាភិបាលជំនួស ត្រូវបំពេញភារកិច្ចដោយគ្មានប្រាក់បៀវត្សរ៍ ប៉ុន្តែធនាគារអាចរ៉ាប់រងរាល់ចំណាយសមរម្យរបស់ទេសាភិបាល និងទេសាភិបាលជំនួស សម្រាប់ការចូលរួមកិច្ចប្រជុំនានា ។

**មាត្រា ២៣.- ក្រុមប្រឹក្សាទេសាភិបាល÷ អំណាច**

១. អំណាចទាំងអស់របស់ធនាគារ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាទេសាភិបាល។

២. ក្រុមប្រឹក្សាទេសាភិបាលអាចធ្វើប្រតិភូកម្មអំណាចមួយចំនួន ឬ ទាំងអស់ ជូនក្រុមប្រឹក្សានាយកប្រតិបត្តិ លើកលែងតែអំណាចមួយចំនួន ដូចខាងក្រោម ÷

(១) សម្រេចលើការសុំចូលរបស់សមាជិកថ្មី និងកំណត់លក្ខខណ្ឌសម្រាប់ការសុំចូលជាសមាជិក

(២) សម្រេចលើការបង្កើន ឬ ការកាត់បន្ថយដើមទុនរបស់ធនាគារ

(៣) សម្រេចលើការផ្អាកសមាជិកភាព

(៤) សម្រេចលើការប្តឹងជំទាស់នឹងការបកស្រាយ ឬ អនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនេះដែលបានធ្វើឡើងដោយក្រុមប្រឹក្សានាយកប្រតិបត្តិ

(៥) បោះឆ្នោតជ្រើសរើសនាយកប្រតិបត្តិរបស់ធនាគារ និងកំណត់មុខចំណាយដែលត្រូវទូទាត់ជូននាយកប្រតិបត្តិ និងនាយកប្រតិបត្តិជំនួស និងប្រាក់បៀវត្សរ៍ ប្រសិនបើមាន ស្របតាមកថាខណ្ឌទី ៦ នៃមាត្រា ២៥

(៦) បោះឆ្នោតជ្រើសរើស ផ្អាក ឬ ដកតំណែង ប្រធានធនាគារ ព្រមទាំងកំណត់ប្រាក់បៀវត្សរ៍ និងលក្ខខណ្ឌការងាររបស់ប្រធានធនាគារ

(៧) អនុម័តលើតារាងតុល្យការ និងរបាយការណ៍ចំណេញ-ខាតរបស់ធនាគារ បន្ទាប់ពីបានពិនិត្យលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុរួច

(៨) សម្រេចលើការកំណត់ទុនបម្រុង និងការវិភាជ និងបែងចែកប្រាក់ចំណេញសុទ្ធរបស់ធនាគារ

(៩) ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ

(១០) សម្រេចលើការបញ្ចប់ប្រតិបត្តិការធនាគារ និងការបែងចែកទ្រព្យសម្បត្តិធនាគារ

(១១) អនុវត្តអំណាចផ្សេងទៀតដែលបានផ្តល់ឱ្យដោយជាក់លាក់ តាមការកំណត់ក្នុងកិច្ចព្រមព្រៀងនេះ ។

៣. ក្រុមប្រឹក្សាទេសាភិបាលនៅតែមានអំណាចពេញលេញ លើរាល់កិច្ចការដែលបានធ្វើប្រតិភូកម្មអំណាចជូនក្រុមប្រឹក្សានាយកប្រតិបត្តិ ដូចមានចែងនៅក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ។

**មាត្រា ២៤.. ក្រុមប្រឹក្សាទេសាភិបាល÷ នីតិវិធី**

១. ក្រុមប្រឹក្សាទេសាភិបាលត្រូវជួបប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់របស់ខ្លួន ឬ តាមការស្នើសុំរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ។ កិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល ត្រូវធ្វើឡើងតាមការស្នើសុំរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ នៅពេលដែលមានសំណើពីសមាជិកយ៉ាងតិចចំនួន ០៥ ។

២. កិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលត្រូវមានកូរ៉ុមគ្រប់ចំនួន ដោយតម្រូវឱ្យមានការចូលរួមពីទេសាភិបាលភាគច្រើន ដែលតំណាងឱ្យសិទ្ធិបោះឆ្នោតយ៉ាងតិច ២/៣ នៃសិទ្ធិបោះឆ្នោតសរុប ។

៣. ក្រុមប្រឹក្សាទេសាភិបាលត្រូវរៀបចំនីតិវិធី ដែលអនុញ្ញាតឱ្យក្រុមប្រឹក្សានាយកប្រតិបត្តិទទួលយកការបោះឆ្នោតរបស់ក្រុមប្រឹក្សាទេសាភិបាលក្នុងការសម្រេចលើបញ្ហាណាមួយ ដោយមិនចាំបាច់ជួបប្រជុំ ឬ ការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាទេសាភិបាល តាមប្រព័ន្ធអេឡិកត្រូនិក ក្នុងកាលៈទេសៈពិសេសមួយចំនួន ។

៤. ក្រុមប្រឹក្សាទេសាភិបាល និងក្រុមប្រឹក្សានាយកប្រតិបត្តិ ក្នុងក្របខណ្ឌនៃសិទ្ធិអំណាចដែលទទួលបានការអនុញ្ញាត អាចបង្កើតអង្គភាពក្រោមឱវាទ និងអនុម័តលើ វិធាននិងបទប្បញ្ញត្តិនានា តាមការចាំបាច់ សម្រាប់ការអនុវត្តកិច្ចប្រតិបត្តិការ របស់ធនាគារ ។

**មាត្រា ២៥.. ក្រុមប្រឹក្សានាយកប្រតិបត្តិ÷ សមាសភាព**

១. ក្រុមប្រឹក្សានាយកប្រតិបត្តិ ត្រូវមានសមាជិកចំនួន ១២ រូប ដែលសមាជិកទាំងនេះ ត្រូវតែមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាទេសាភិបាល និងត្រូវមានសមាសភាព ដូចខាងក្រោម÷

(១) ០៩ រូបត្រូវបោះឆ្នោតជ្រើសតាំងដោយទេសាភិបាលនៃសមាជិកក្នុងតំបន់ និង

(២) ០៣ រូបត្រូវបោះឆ្នោតជ្រើសតាំងដោយទេសាភិបាលនៃសមាជិកក្រៅតំបន់ ។

នាយកប្រតិបត្តិត្រូវតែជាបុគ្គលដែលមានសមត្ថភាពខ្ពស់ផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងត្រូវបានបោះឆ្នោតជ្រើសតាំងស្របតាមឧបសម្ព័ន្ធ "ខ" ។ នាយកប្រតិបត្តិត្រូវតំណាងឱ្យប្រទេសជាសមាជិកដែលទេសាភិបាលនៃប្រទេសនោះ បានបោះឆ្នោតជូនខ្លួន ឬ បានចាត់តាំងខ្លួនឱ្យបោះឆ្នោតតំណាងពួកគេ។

២. ក្រុមប្រឹក្សាទេសាភិបាលត្រូវពិនិត្យឡើងវិញជាប្រចាំលើចំនួន និងសមាសភាពនៃក្រុមប្រឹក្សានាយកប្រតិបត្តិ និងអាចសម្រេច បង្កើន ឬ បន្ថយចំនួន ឬ កែសម្រួលសមាសភាពតាមការចាំបាច់ តាមរយៈការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

៣. នាយកប្រតិបត្តិនីមួយៗ ត្រូវតែងតាំងនាយកប្រតិបត្តិជំនួស ដែលនឹងមានសិទ្ធិពេញសមត្ថភាពក្នុងការបំពេញភារកិច្ចជំនួស នៅពេលដែលនាយកប្រតិបត្តិអវត្តមាន ។ ក្រុមប្រឹក្សាទេសាភិបាល ត្រូវអនុម័តវិធានដែលអនុញ្ញាតឱ្យនាយកប្រតិបត្តិដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជិកច្រើនលើសពីចំនួនណាមួយជាកំណត់មានសិទ្ធិតែងតាំងនាយកប្រតិបត្តិជំនួសបន្ថែមលើសពី ០១ រូប បាន ។

៤. នាយកប្រតិបត្តិ និងនាយកប្រតិបត្តិជំនួស ត្រូវតែមានសញ្ជាតិនៃប្រទេសជាសមាជិក ។ មិនត្រូវបានអនុញ្ញាតឱ្យនាយកប្រតិបត្តិ ២ រូប ឬ ច្រើនរូប មានសញ្ជាតិដូចគ្នាទេ និងក៏មិនត្រូវបានអនុញ្ញាតឱ្យនាយកប្រតិបត្តិជំនួស ២ រូប ឬ ច្រើនរូប មានសញ្ជាតិដូចគ្នាដែរ ។ នាយកប្រតិបត្តិជំនួស អាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សានាយកប្រតិបត្តិបាន ប៉ុន្តែមានសិទ្ធិបោះឆ្នោតតែក្នុងករណីដែលចូលរួមក្នុងនាមនាយកប្រតិបត្តិតែប៉ុណ្ណោះ ។

៥. នាយកប្រតិបត្តិមានអាណត្តិ ២ ឆ្នាំ ហើយអាចឈរឈ្មោះឱ្យគេបោះឆ្នោតឡើងវិញទៀតបាន ។

ក. នាយកប្រតិបត្តិត្រូវបន្តបំពេញភារកិច្ចរហូតដល់នាយកប្រតិបត្តិថ្មីត្រូវបានជ្រើសតាំង និងចាប់ផ្តើមចូលបំពេញភារកិច្ច ។

ខ. ក្នុងករណីដែលមុខតំណែងនាយកប្រតិបត្តិស្ថិតក្នុងភាពទំនេររយៈពេលច្រើនជាង ១៨០ ថ្ងៃ មុនពេលត្រូវបញ្ចប់អាណត្តិ នាយកប្រតិបត្តិថ្មីនឹងត្រូវបានជ្រើសតាំងស្របតាមឧបសម្ព័ន្ធ "ខ" សម្រាប់បំពេញការងារក្នុងរយៈពេលដែលនៅសល់ រហូតបញ្ចប់អាណត្តិ ។ ការបោះឆ្នោតជ្រើសតាំងនេះ ត្រូវធ្វើឡើងដោយទេសាភិបាលដែលបានជ្រើសតាំងអតីតនាយកប្រតិបត្តិ តាមរយៈការបោះឆ្នោតដោយមតិភាគច្រើន ។ ទេសាភិបាលដែលបានជ្រើសតាំងអតីតនាយកប្រតិបត្តិ ក៏អាចសម្រេចយកវិធីបោះឆ្នោតដើម្បីជ្រើសតាំងនាយកប្រតិបត្តិថ្មីបានដែរ បើទោះជាតំណែងនាយកប្រតិបត្តិស្ថិតក្នុងភាពទំនេរត្រឹម ១៨០ ថ្ងៃ ឬ តិចជាងនេះ គិតរហូតដល់ពេលបញ្ចប់អាណត្តិក៏ដោយ ។

គ. ក្នុងរយៈពេលដែលមុខតំណែងនាយកប្រតិបត្តិនៅតែបន្តទំនេរ នាយកប្រតិបត្តិជំនួសនៃអតីតនាយកប្រតិបត្តិ ត្រូវបន្តបំពេញភារកិច្ចជំនួសនាយកប្រតិបត្តិថ្មី លើកលែងតែសិទ្ធិតែងតាំងនាយកប្រតិបត្តិជំនួស ។

៦. នាយកប្រតិបត្តិ និងនាយកប្រតិបត្តិជំនួស ត្រូវបំពេញភារកិច្ចដោយគ្មានប្រាក់បៀវត្សរ៍ពីធនាគារ លើកលែងតែមានការសម្រេចដោយឡែកផ្សេងពីនេះ ដោយក្រុមប្រឹក្សាទេសាភិបាល ប៉ុន្តែធនាគារអាចរ៉ាប់រងរាល់ការចំណាយសមរម្យសម្រាប់ការចូលរួមកិច្ចប្រជុំនានា ។



ꩡ

**មាត្រា ២៦.. ក្រុមប្រឹក្សានាយកប្រតិបត្តិ÷ អំណាច**

ក្រុមប្រឹក្សានាយកប្រតិបត្តិ ត្រូវមានភារកិច្ចដឹកនាំកិច្ចប្រតិបត្តិការទូទៅរបស់ធនាគារ ។ ក្នុងហេតុផលនេះ បន្ថែមលើអំណាចដែលត្រូវផ្តល់ជូនដោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សានាយកប្រតិបត្តិ ត្រូវអនុវត្តអំណាចដែលផ្តល់ប្រតិភូកម្មដោយក្រុមប្រឹក្សាទេសាភិបាល និង ជាអាទិ៍ ÷

(១) រៀបចំការងារសម្រាប់ក្រុមប្រឹក្សាទេសាភិបាល

(២) បង្កើតគោលនយោបាយរបស់ធនាគារ និងធ្វើសេចក្តីសម្រេចស្តីពី÷ គោលនយោបាយពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការសំខាន់ៗ និងហិរញ្ញវត្ថុរបស់ធនាគារ និងការធ្វើប្រតិភូកម្មអំណាចជូនប្រធានធនាគារក្នុងការប្រតិបត្តិគោលនយោបាយទាំងនេះ ។ ការធ្វើសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងតាមការបោះឆ្នោតដោយមតិភាគច្រើនយ៉ាងតិច ៣/៤ នៃសិទ្ធិបោះឆ្នោតសរុបរបស់សមាជិក ។

(៣) ធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងរាល់ប្រតិបត្តិការនានារបស់ធនាគារ ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១១ និងសម្រេចលើការធ្វើប្រតិភូកម្មជូនប្រធានធនាគារ ក្នុងការអនុវត្តកិច្ចប្រតិបត្តិការទាំងនេះ ។ ការធ្វើសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងតាមការបោះឆ្នោតដោយមតិភាគច្រើនយ៉ាងតិច ៣/៤ នៃសិទ្ធិបោះឆ្នោតសរុបរបស់សមាជិក ។

(៤) ត្រួតពិនិត្យជាប្រចាំលើការគ្រប់គ្រង និងកិច្ចប្រតិបត្តិការរបស់ធនាគារ ព្រមទាំងបង្កើតយន្តការក្នុងការត្រួតពិនិត្យ ស្របតាមគោលការណ៍តម្លាភាព បើកចំហ ឯករាជ្យភាព និងគណនេយ្យភាព ។

(៥) អនុម័តលើយុទ្ធសាស្ត្រ ផែនការ និងថវិកាប្រចាំឆ្នាំរបស់ធនាគារ ។

(៦) ចាត់តាំងគណៈកម្មាធិការនានាតាមការចាំបាច់ ។

(៧) ដាក់ជូនក្រុមប្រឹក្សាទេសាភិបាលពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មរួច ។

**មាត្រា ២៧.. ក្រុមប្រឹក្សានាយកប្រតិបត្តិ÷ នីតិវិធី**

១. ក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវជួបប្រជុំជាប្រចាំ និងញឹកញាប់តាមការចាំបាច់ ដើម្បីទ្រទ្រង់កិច្ចប្រតិបត្តិការរបស់ធនាគារ ។ ក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវបំពេញភារកិច្ចជាលក្ខណៈអនិវាសនដ្ឋាន លើកលែងតែមានការសម្រេចដោយឡែកផ្សេងពីនេះ របស់ក្រុមប្រឹក្សាទេសាភិបាល ដោយមតិភាគច្រើនលើសលប់ ស្របតាមមាត្រា ២៨ ។ កិច្ចប្រជុំអាចត្រូវបានកោះហៅដោយប្រធាន ឬ តាមសំណើរបស់នាយកប្រតិបត្តិយ៉ាងតិច ០៣ រូប ។

២. កិច្ចប្រជុំក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវមានកូរ៉ុមគ្រប់ចំនួន ដោយតម្រូវឱ្យមានការចូលរួមពីនាយកប្រតិបត្តិភាគច្រើន ដែលតំណាងឱ្យសិទ្ធិបោះឆ្នោតយ៉ាងតិច ២/៣ នៃសិទ្ធិបោះឆ្នោតសរុប ។

៣. ក្រុមប្រឹក្សាទេសាភិបាលត្រូវអនុម័តបទប្បញ្ញត្តិ ស្តីពីការអនុញ្ញាតឱ្យសមាជិកមានសិទ្ធិបញ្ជូនអ្នកតំណាងទៅចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ក្នុងករណីមានការពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងប្រទេសជាសមាជិកដែលពុំមាននាយកប្រតិបត្តិជាសញ្ជាតិនៃប្រទេសរបស់ខ្លួន ។ អ្នកតំណាងពុំត្រូវមានសិទ្ធិបោះឆ្នោតក្នុងកិច្ចប្រជុំទេ ។

៤. ក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវកំណត់នីតិវិធីដែលអនុញ្ញាតឱ្យក្រុមប្រឹក្សានាយកប្រតិបត្តិ អាចប្រជុំតាមប្រព័ន្ធអេឡិកត្រូនិក ឬ បោះឆ្នោតសម្រេចដោយមិនចាំបាច់ជួបប្រជុំ ។

**មាត្រា ២៨.- ការបោះឆ្នោត**

១. សិទ្ធិបោះឆ្នោតរបស់សមាជិកនីមួយៗត្រូវកើតឡើងពីផលបូកសរុបនៃសិទ្ធិបោះឆ្នោតមូលដ្ឋាន សិទ្ធិបោះឆ្នោតតាមភាគហ៊ុន និងសិទ្ធិបោះឆ្នោតសមាជិកស្ថាបនិក ក្នុងករណីជាសមាជិកស្ថាបនិក ។

(១) សិទ្ធិបោះឆ្នោតមូលដ្ឋានរបស់សមាជិកនីមួយៗ គឺជាចំនួនសិទ្ធិបោះឆ្នោតដែលត្រូវបានបែងចែកស្មើគ្នារវាងសមាជិកទាំងអស់ ដែលមានចំនួនសមាមាត្រសរុប ១២% នៃសិទ្ធិបោះឆ្នោតទាំងអស់ ។

(២) ចំនួនសិទ្ធិបោះឆ្នោតតាមភាគហ៊ុនរបស់សមាជិកនីមួយៗ ត្រូវស្មើនឹងចំនួននៃភាគហ៊ុនដែលសមាជិកកាន់កាប់ ក្នុងដើមទុនរបស់ធនាគារ ។

(៣) សមាជិកស្ថាបនិកនីមួយៗ ត្រូវបានផ្តល់ជូននូវសិទ្ធិបោះឆ្នោតសមាជិកស្ថាបនិកចំនួន ៦០០ ស្មើៗគ្នា ។

ក្នុងករណីសមាជិកណាមួយ ខកខានមិនបានបង់គ្រប់ចំនួនទៅតាមកាតព្វកិច្ចនៃភាគហ៊ុនត្រូវបង់ ដូចមានចែងក្នុងមាត្រា ៦ សមាជិកនោះនឹងត្រូវបានកាត់បន្ថយសិទ្ធិបោះឆ្នោតតាមភាគហ៊ុន ទៅតាមសមាមាត្រនៃចំនួនភាគហ៊ុនដែលនៅមិនទាន់បានបង់ ។

២. ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល ទេសាភិបាលនីមួយៗត្រូវបោះឆ្នោតសម្រេចក្នុងនាមប្រទេសជាសមាជិកដែលខ្លួនតំណាងឱ្យ ។

(១) លើកលែងតែមានការចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាលត្រូវធ្វើឡើងតាមការបោះឆ្នោតដោយមតិភាគច្រើន ។

(២) ការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ តម្រូវឱ្យមានសម្លេងគាំទ្រ ២/៣ នៃចំនួនទេសាភិបាលសរុប ដែលតំណាងឱ្យសិទ្ធិបោះឆ្នោតយ៉ាងតិច ៣/៤ នៃសិទ្ធិបោះឆ្នោតសរុប ។

(៣) ការបោះឆ្នោតដោយមតិភាគច្រើនពិសេស តម្រូវឱ្យមានសម្លេងគាំទ្រភាគច្រើននៃចំនួនទេសាភិបាលសរុប ដែលតំណាងឱ្យសិទ្ធិបោះឆ្នោតភាគច្រើននៃសិទ្ធិបោះឆ្នោតសរុប ។

៣. ចំពោះការបោះឆ្នោតក្នុងក្រុមប្រឹក្សានាយកប្រតិបត្តិ នាយកប្រតិបត្តិនីមួយៗមានសិទ្ធិបោះឆ្នោតទៅតាមចំនួនសិទ្ធិបោះឆ្នោតនៃទេសាភិបាលដែលបានជ្រើសតាំងខ្លួន និងចំនួននៃសិទ្ធិបោះឆ្នោតនៃទេសាភិបាលដែលបានចាត់តាំងខ្លួនឱ្យបោះឆ្នោតតំណាង ដូចមានចែងក្នុងឧបសម្ព័ន្ធ "ខ" ។

(១) នាយកប្រតិបត្តិដែលតំណាងឱ្យសមាជិកចាប់ពី០១ ឡើង អាចបោះឆ្នោតតំណាងឱ្យសមាជិកនីមួយៗដាច់ដោយឡែកពីគ្នាបាន

(២) លើកលែងតែមានការចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ រាល់ការសម្រេចរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវធ្វើឡើងតាមការបោះឆ្នោតដោយមតិភាគច្រើន ។

**មាត្រា ២៩.- ប្រធាន**

១. ក្រុមប្រឹក្សាទេសាភិបាល ត្រូវជ្រើសតាំងប្រធានធនាគារតាមគោលការណ៍បើកចំហ តម្លាភាព និងផ្អែកលើសមត្ថភាព តាមរយៈការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងក្នុងមាត្រា ២៨ ។ ប្រធានធនាគារ

ត្រូវមានសញ្ជាតិនៃប្រទេសជាសមាជិកក្នុងតំបន់ ។ ប្រធានធនាគារ មិនត្រូវបំពេញមុខងារជាទេសាភិបាល នាយកប្រតិបត្តិ ឬ នាយកប្រតិបត្តិជំនួសឡើយ ។

២. អាណត្តិរបស់ប្រធានធនាគារ មានរយៈពេល ០៥ ឆ្នាំ ។ ប្រធានធនាគារ អាចត្រូវបានបោះឆ្នោតជ្រើសតាំងឡើងវិញម្តងទៀតបាន ។ ប្រធានធនាគារ អាចត្រូវបានផ្អាក ឬ ដកចេញពីតំណែងតាមការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល ដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

(ក) ក្នុងករណីតំណែងប្រធានធនាគារ ស្ថិតក្នុងភាពទំនេរដោយហេតុផលណាមួយ ក្រុមប្រឹក្សាទេសាភិបាលត្រូវចាត់តាំងប្រធានស្តីទី សម្រាប់រយៈពេលបណ្តោះអាសន្ន ឬ បោះឆ្នោតជ្រើសតាំងប្រធានថ្មី ស្របតាមកថាខណ្ឌទី ១ នៃមាត្រានេះ ។

៣. ប្រធានធនាគារ ជាប្រធានក្រុមប្រឹក្សានាយកប្រតិបត្តិ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោត លើកលែងតែករណីដែលលទ្ធផលបោះឆ្នោតរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិមានសម្លេងស្មើគ្នា ។ ប្រធានធនាគារ អាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាលបាន ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោត ។

៤. ប្រធានធនាគារ គឺជាតំណាងស្របច្បាប់របស់ធនាគារ ។ ប្រធានធនាគារ ជាប្រធាននៃមន្ត្រីរបស់ធនាគារ ហើយត្រូវបំពេញភារកិច្ចតាមការណែនាំរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ក្នុងការបំពេញកិច្ចការប្រចាំថ្ងៃរបស់ធនាគារ ។

**មាត្រា ៣០.. មន្ត្រី និងបុគ្គលិករបស់ធនាគារ**

១. អនុប្រធានធនាគារមួយ ឬ ច្រើនរូប ត្រូវតែងតាំងដោយក្រុមប្រឹក្សានាយកប្រតិបត្តិ ផ្អែកតាមអនុសាសន៍របស់ប្រធានធនាគារ និងត្រូវជ្រើសរើសដោយផ្អែកលើគោលការណ៍បើកចំហ តម្លាភាព និងសមត្ថភាព ។ អនុប្រធានធនាគារ ត្រូវបំពេញភារកិច្ចក្នុងអាណត្តិរបស់ខ្លួនទៅតាមមុខងារ និងសិទ្ធិអំណាចក្នុងរដ្ឋបាលរបស់ធនាគារ អាស្រ័យតាមការចាត់តាំងរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ។ ក្នុងករណីដែលប្រធានធនាគារអវត្តមាន ឬ បាត់បង់សមត្ថភាពការងារ អនុប្រធានមួយរូប ត្រូវបំពេញភារកិច្ចជំនួសប្រធាន ។

២. ប្រធានធនាគារត្រូវទទួលខុសត្រូវលើការចាត់ចែង តែងតាំង និងដកតំណែងមន្ត្រី និងបុគ្គលិករបស់ធនាគារ ស្របតាមវិធានដែលអនុម័តដោយក្រុមប្រឹក្សានាយកប្រតិបត្តិ លើកលែងតែចំពោះករណីអនុប្រធានធនាគារដែលត្រូវអនុវត្តតាមវិធានដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ។

៣. ប្រធានធនាគារត្រូវតែងតាំងមន្ត្រី ឬ បុគ្គលិក និងផ្តល់អនុសាសន៍លើការតែងតាំងអនុប្រធានធនាគារ ដោយគោរពតាមគោលការណ៍ស្តង់ដារខ្ពស់បំផុតនៃប្រសិទ្ធភាព និងសមត្ថភាពបច្ចេកទេស ព្រមទាំងយកចិត្តទុកដាក់លើការជ្រើសរើសបុគ្គលិកពីភូមិសាស្ត្រក្នុងតំបន់ ឱ្យបានទូលាយតាមដែលអាចធ្វើបាន ។

**មាត្រា ៣១.. ចរិតលក្ខណៈជាអន្តរជាតិរបស់ធនាគារ**

១. ធនាគារមិនអាចទទួលយកមូលនិធិពិសេស ឥណទាន ឬ ជំនួយណាមួយ ដែលអាចនឹងបណ្តាលឱ្យប៉ះពាល់ដាក់កំហិត ឬ បង្កជាឧបសគ្គណាមួយ ដល់ការបំពេញមុខងារ និងគោលបំណងរបស់ធនាគារបានឡើយ ។

២. ធនាគារ ប្រធានធនាគារ មន្ត្រី និងបុគ្គលិករបស់ធនាគារ មិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការនយោបាយរបស់ប្រទេសជាសមាជិកឡើយ ហើយក៏មិនត្រូវទទួលរងឥទ្ធិពលនយោបាយពីប្រទេសជាសមាជិក ក្នុងការធ្វើសេចក្តី

សម្រេចឡើយ ។ មានតែកត្តាសេដ្ឋកិច្ចប៉ុណ្ណោះ ដែលជាមូលដ្ឋាននៃការធ្វើសេចក្តីសម្រេច ក្នុងការបំពេញមុខងារ និង សម្រេចគោលបំណងរបស់ធនាគារ ។

៣. ប្រធានធនាគារ មន្ត្រី និងបុគ្គលិកធនាគារ នៅក្នុងមុខតំណែងរបស់ខ្លួន ត្រូវមានភារកិច្ចបំពេញការងារជូនធនាគារតែប៉ុណ្ណោះ ដោយមិនត្រូវបម្រើឱ្យអាជ្ញាធរដទៃណាផ្សេងទៀតឡើយ ។ សមាជិកនីមួយៗរបស់ធនាគារ ត្រូវគោរពចរឹកលក្ខណៈជាអន្តរជាតិរបស់ធនាគារ ក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនត្រូវព្យាយាមប្រើប្រាស់ឥទ្ធិពលណាមួយ ចូលជ្រៀតជ្រែកលើការបំពេញមុខងាររបស់ធនាគារឡើយ ។

## ជំពូកទី ៦

## បទប្បញ្ញត្តិទូទៅ

### មាត្រា ៣២.. ទីស្នាក់ការរបស់ធនាគារ

១. ទីស្នាក់ការកណ្តាលរបស់ធនាគារ ត្រូវស្ថិតនៅរដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ។

២. ធនាគារអាចបង្កើតទីភ្នាក់ងារ ឬ ការិយាល័យនៅកន្លែងផ្សេងទៀតបាន ។

### មាត្រា ៣៣.. បណ្តាញទំនាក់ទំនង និងការតម្កល់ទុក

១. សមាជិកនីមួយៗត្រូវចាត់តាំងស្ថាប័នជាផ្លូវការរបស់ខ្លួន សម្រាប់ធ្វើទំនាក់ទំនងជាមួយធនាគារលើរាល់កិច្ចការពាក់ព័ន្ធដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ។

២. សមាជិកនីមួយៗត្រូវចាត់តាំងធនាគារកណ្តាលរបស់ខ្លួន ឬ ស្ថាប័នប្រហាក់ប្រហែលផ្សេងទៀតដោយមានការឯកភាពជាមួយធនាគារ ជាស្ថាប័នតម្កល់ ដែលធនាគារអាចរក្សាទុករូបិយវត្ថុនៃសមាជិកនោះ ឬ ទ្រព្យផ្សេងទៀតបាន ។

៣. ធនាគារអាចរក្សាទុកទ្រព្យរបស់ខ្លួននៅស្ថាប័នតម្កល់នេះ តាមការសម្រេចរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ។

### មាត្រា ៣៤.. របាយការណ៍ និងព័ត៌មាន

១. ភាសាប្រើប្រាស់ជាផ្លូវការរបស់ធនាគារ គឺភាសាអង់គ្លេស ហើយធនាគារត្រូវផ្អែកលើអត្ថបទជាភាសាអង់គ្លេសនៃកិច្ចព្រមព្រៀងនេះ ក្នុងការធ្វើរាល់សេចក្តីសម្រេច និងបកស្រាយខ្លឹមសារទាំងឡាយ ដូចមានចែងក្នុងមាត្រា ៥៤ ។

២. សមាជិកត្រូវផ្តល់ជូនធនាគារនូវរាល់ព័ត៌មានចាំបាច់នានា តាមការស្នើសុំ ដើម្បីសម្រួលដល់ការបំពេញមុខងាររបស់ធនាគារ ។

៣. ធនាគារត្រូវផ្ញើរជូនសមាជិកនូវរបាយការណ៍ប្រចាំឆ្នាំ ដែលក្នុងនោះមានទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និងត្រូវផ្សព្វផ្សាយជាសាធារណៈ ។ ធនាគារត្រូវផ្ញើរជូនសមាជិកនូវរបាយការណ៍សង្ខេបប្រចាំត្រីមាសស្តីពីស្ថានភាពហិរញ្ញវត្ថុ និង របាយការណ៍ចំណេញ -ខាត ដែលឆ្លុះបញ្ចាំងអំពីលទ្ធផលនៃកិច្ចប្រតិបត្តិការរបស់ធនាគារ ។

៤.  ធនាគារត្រូវរៀបចំគោលនយោបាយស្តីពីការបើកចំហរព័ត៌មាន ដើម្បីលើកកម្ពស់តម្លាភាពនៃកិច្ចប្រតិបត្តិការ ។ ធនាគារអាចផ្សព្វផ្សាយនូវរបាយការណ៍នានាតាមការចាំបាច់ ក្នុងកិច្ចប្រតិបត្តិការមុខងារ និងគោលបំណងរបស់ខ្លួន ។

**មាត្រា ៣៥.. កិច្ចសហប្រតិបត្តិការជាមួយសមាជិក និងអង្គការអន្តរជាតិ**

១.  ធនាគារត្រូវបំពេញបេសកកម្មរបស់ខ្លួន ដោយធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយសមាជិកទាំងអស់ និង ក្នុងករណីដែលធនាគារយល់ថាសមស្របតាមខ្លឹមសារដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ  ធនាគារក៏ត្រូវធ្វើកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដទៃទៀត  ក៏ដូចជាអង្គការអន្តរជាតិនានាដែលបំពេញបេសកកម្មលើកិច្ចការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ឬ ក្នុងវិស័យដែលស្ថិតក្រោមប្រតិបត្តិការរបស់ធនាគារ ។

២.  ធនាគារអាចចូលរួមធ្វើកិច្ចប្រតិបត្តិការជាមួយស្ថាប័នទាំងនេះ  ដើម្បីអនុវត្តគោលបំណងនានាដែលស្រប តាមកិច្ចព្រមព្រៀងនេះ និងតាមការសម្រេចរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ។

**មាត្រា ៣៦.. ការយោង**

១.  រាល់ការយោងក្នុងកិច្ចព្រមព្រៀងនេះ ទៅ "មាត្រា" ឬ "ឧបសម្ព័ន្ធ" សំដៅដល់ "មាត្រា" និង "ឧបសម្ព័ន្ធ" នៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការចែងផ្សេងពីនេះ ។

២.  "ភេទ" ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ គឺសំដៅដល់ការអនុវត្តដោយស្មើភាពចំពោះគ្រប់ភេទ ។

## ជំពូកទី ៧

## ការដក និង ការផ្អាកសមាជិកភាព

**មាត្រា ៣៧.. ការដកសមាជិកភាព**

១.  សមាជិក  អាចដកសមាជិកភាពរបស់ខ្លួនពីធនាគារ  នៅពេលណាមួយក៏បាន  តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅធនាគារនៅទីស្នាក់ការកណ្តាល ។

២.  ការដកសមាជិកភាពរបស់សមាជិក  ត្រូវចូលជាធរមាន  ហើយសមាជិកភាពនោះនឹងត្រូវបានបញ្ចប់នៅ កាលបរិច្ឆេទដែលបានកំណត់ក្នុងលិខិតជូនដំណឹងរបស់សមាជិក ប៉ុន្តែកាលបរិច្ឆេទនេះ មិនត្រូវមានរយៈពេលតិចជាង ៦ ខែ គិតចាប់ពីកាលបរិច្ឆេទដែលធនាគារបានទទួលលិខិតជាផ្លូវការ ។ ទោះជាយ៉ាងណា ក្នុងរយៈពេលនេះ សមាជិកអាចធ្វើមោឃភាពលើការដកសមាជិកភាពរបស់ខ្លួនវិញបាន  តាមរយៈលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ។

៣.  សមាជិកដែលស្នើសុំដកសមាជិកភាព  នៅតែទទួលខុសត្រូវចំពោះកាតព្វកិច្ចដោយផ្ទាល់  និងជាយថាហេតុនានាដែលខ្លួនត្រូវទទួលខុសត្រូវចំពោះចំពោះធនាគារ រហូតត្រឹមថ្ងៃប្រគល់លិខិតសុំដកសមាជិកភាព ។ ក្នុងករណីសំណើសុំដកសមាជិកភាពបានចូលជាធរមាន សមាជិកត្រូវរួចផុតពីរាល់កាតព្វកិច្ចនានា ដែលកើតចេញពីប្រតិបត្តិការរបស់ធនាគារ ដែលបានកើតឡើងបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលលិខិតស្នើសុំដកសមាជិកភាព ។

**មាត្រា ៣៨.. ការផ្អាកសមាជិកភាព**

១. ក្នុងករណីសមាជិកណាមួយ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះធនាគារ ក្រុមប្រឹក្សាទេសាភិបាលអាចសម្រេចផ្អាកសមាជិកភាព តាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

២. សមាជិកដែលត្រូវបានផ្អាកសមាជិកភាព នឹងត្រូវបញ្ចប់សមាជិកភាពជាស្វ័យប្រវត្តិក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផ្អាក លើកលែងតែមានការសម្រេចផ្សេងពីនេះដោយក្រុមប្រឹក្សាទេសាភិបាល តាមមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ដើម្បីស្តារស្ថានភាពរបស់សមាជិកនោះឱ្យមានសមាជិកភាពធម្មតាវិញ ។

៣. ក្នុងរយៈពេលនៃការផ្អាកសមាជិកភាព សមាជិកមិនអាចប្រើប្រាស់សិទ្ធិណាមួយរបស់ខ្លួន ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះបានទេ លើកលែងតែសិទ្ធិក្នុងការស្នើសុំដកសមាជិកភាព ។ ទោះជាយ៉ាងណា សមាជិកនោះ នៅតែត្រូវបន្តទទួលខុសត្រូវលើរាល់កាតព្វកិច្ចរបស់ខ្លួនដដែល ។

**មាត្រា ៣៩.. ការទូទាត់គណនី**

១. បន្ទាប់ពីកាលបរិច្ឆេទដែលប្រទេសណាមួយត្រូវបានបញ្ចប់សមាជិកភាព ប្រទេសជាអតីតសមាជិកនៅតែត្រូវទទួលខុសត្រូវលើរាល់កាតព្វកិច្ចដោយផ្ទាល់ចំពោះធនាគារ និងកាតព្វកិច្ចជាយថាហេតុដែលកើតចេញពីចំណែកនៃឥណទាន ការធានា ការវិនិយោគលើទ្រព្យមូលធន ឬ ការធ្វើហិរញ្ញប្បទានក្រោមទម្រង់ផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ២ (ចំណុច ៦) នៃមាត្រា ១១ ដែលធនាគារបានចុះកិច្ចសន្យាមុនកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាព ហើយនៅមិនទាន់បានទូទាត់អស់ ។ ប្រទេសជាអតីតសមាជិក មិនត្រូវទទួលខុសត្រូវលើកាតព្វកិច្ចជាយថាហេតុដែលកើតចេញពីឥណទាន ការធានា ការវិនិយោគលើទ្រព្យមូលធន ឬ ហិរញ្ញប្បទានក្រោមទម្រង់ផ្សេងទៀត ដែលធនាគារបានចុះកិច្ចសន្យាក្រោយកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាព ហើយក៏មិនទទួលខុសត្រូវចំពោះរាល់ចំណូល - ចំណាយនានារបស់ធនាគារដែរ ។

២. នៅខណៈពេលដែលប្រទេសណាមួយត្រូវបានបញ្ចប់សមាជិកភាព ធនាគារត្រូវចាត់ចែងទិញភាគហ៊ុនរបស់ប្រទេសនោះត្រឡប់មកវិញ ដែលជាផ្នែកមួយនៃកិច្ចដំណើរការជម្រះបញ្ជី ស្របតាមបទប្បញ្ញត្តិនៃកថាខណ្ឌទី ៣ និងទី ៤ នៃមាត្រានេះ ។ ក្នុងគោលដៅនេះ តម្លៃនៃការទិញភាគហ៊ុនត្រឡប់វិញ គឺត្រូវកំណត់យកតម្លៃដែលបានចុះក្នុងបញ្ជីគណនេយ្យរបស់ធនាគារ នាកាលបរិច្ឆេទបញ្ចប់សមាជិកភាព ។

៣. ការទូទាត់ចំពោះការទិញភាគហ៊ុនត្រឡប់វិញដោយធនាគារ ត្រូវអនុលោមតាមលក្ខខណ្ឌ ដូចខាងក្រោម÷

(១) ត្រូវកាត់ទុកនូវទឹកប្រាក់មួយចំនួន ដែលប្រទេសនោះ ឬ ធនាគារកណ្តាល ទីភ្នាក់ងារ ឬ ស្ថាប័នថ្នាក់ក្រោមជាតិនៃប្រទេសនោះ ជាប់កាតព្វកិច្ចចំពោះធនាគារ ក្នុងនាមជាឥណទាយិក ឬ អ្នកធានា ឬ ជាគូភាគីនៃកិច្ចសន្យាលើការវិនិយោគទ្រព្យមូលធន ឬ ការធ្វើហិរញ្ញប្បទានក្រោមទម្រង់ផ្សេងទៀត ហើយតាមការសម្រេចរបស់ធនាគារ អាចកាត់កងនូវចំនួនទាំងនេះ នៅពេលដល់ឥណប្រតិទាន ។ មិនត្រូវបានអនុញ្ញាតឱ្យកាត់ទុកចេញពីគណនីនៃកាតព្វកិច្ចជាយថាហេតុរបស់ប្រទេសនោះ សម្រាប់ការកោះហៅឱ្យបង់ភាគហ៊ុននាពេលអនាគត ដែលមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៦ ទេ ។ ក្នុងគ្រប់ករណីទាំងអស់ ការទូទាត់

សម្រាប់ការទិញភាគហ៊ុនត្រឡប់វិញ មិនអាចត្រូវធ្វើឡើងក្នុងរយៈពេលតិចជាង ៦ ខែ គិតចាប់ពីកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាព ។

(២) ការទូទាត់លើការទិញភាគហ៊ុនត្រឡប់វិញ អាចត្រូវធ្វើឡើងជាដំណាក់កាលបន្តបន្ទាប់បាន នាគ្រប់ពេលនៃការប្រគល់វិញ្ញាបនប័ត្រភាគហ៊ុនដែលពាក់ព័ន្ធដោយប្រទេសសាមី ក្នុងលក្ខខណ្ឌដែលទឹកប្រាក់សមតុល្យនៃភាគហ៊ុនដែលធនាគារត្រូវទិញត្រឡប់វិញ ស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ មានចំនួនលើសពីតម្លៃសរុបនៃកាតព្វកិច្ចទទួលខុសត្រូវចំពោះធនាគារពាក់ព័ន្ធនឹងឥណទាន ការធានា ការវិនិយោគទ្រព្យមូលធន និងការធ្វើហិរញ្ញប្បទានក្រោមទម្រង់ផ្សេងទៀតដូចមានចែងក្នុងអនុកថាខណ្ឌទី ១ នៃកថាខណ្ឌនេះ រហូតដល់ពេលដែលអតីតសមាជិកនោះបានទទួលការបង់ប្រាក់ថ្លៃទិញភាគហ៊ុនត្រឡប់វិញគ្រប់ចំនួន ។

(៣) ការទូទាត់ត្រូវធ្វើឡើងតាមរូបិយប័ណ្ណណាមួយ តាមការកំណត់របស់ធនាគារ ផ្អែកលើស្ថានភាពហិរញ្ញវត្ថុជាក់ស្តែង ។

(៤) ក្នុងករណីដែលធនាគាររងការខាតបង់ដោយសារ ឥណទាន ការធានា ការវិនិយោគលើទ្រព្យមូលធន ឬហិរញ្ញប្បទានផ្សេងទៀត ដែលនៅមិនទាន់បានទូទាត់អស់ គិតត្រឹមកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាព ហើយដែលទំហំទឹកប្រាក់ខាតបង់នេះ លើសពីចំនួនដែលបានត្រៀមបម្រុងសម្រាប់ការខាតបង់នាកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាព ប្រទេសនោះត្រូវបង់ត្រឡប់វិញតាមសំណើរបស់ធនាគារ នូវចំនួនដែលនៅខ្វះ ដើម្បីបង្គ្រប់តាមចំនួនខាតបង់ ។ លើសពីនេះ អតីតសមាជិកត្រូវបន្តទទួលខុសត្រូវ ចំពោះការកោះហៅឱ្យបង់ប្រាក់ចំពោះភាគហ៊ុនដែលបានទិញ ប៉ុន្តែមិនទាន់បានបង់ប្រាក់ស្របតាមកថាខណ្ឌទី ៣ នៃមាត្រា ៦ ទៅតាមទំហំដែលខ្លួនគួរត្រូវបង់ ក្នុងឋានៈជាសមាជិក ក្នុងករណីដែលធនាគារមានឱនភាពដើមទុន ហើយការកោះហៅឱ្យបង់ប្រាក់នេះត្រូវបានធ្វើឡើងនៅពេលដែលតម្លៃភាគហ៊ុនត្រូវទិញត្រឡប់វិញត្រូវបានកំណត់ ។

៤. ក្នុងករណីដែលធនាគារបញ្ឈប់ប្រតិបត្តិការរបស់ខ្លួន ស្របតាមមាត្រា ៤១ ក្នុងរយៈពេល ៦ ខែ គិតពីកាលបរិច្ឆេទនៃការបញ្ចប់សមាជិកភាពនៃប្រទេសណាមួយ រាល់សិទ្ធិទាំងឡាយរបស់សមាជិកដែលពាក់ព័ន្ធនោះត្រូវកំណត់អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៤១ រហូតដល់ ៤៣ ។ ប្រទេសនោះ ត្រូវចាត់ទុកថា នៅតែជាសមាជិកសម្រាប់តែគោលដៅនៃមាត្រាទាំងនេះ ប៉ុន្តែគ្មានសិទ្ធិបោះឆ្នោតទេ ។

## ជំពូកទី ៨
## ការផ្អាក និងការបញ្ឈប់ប្រតិបត្តិការរបស់ធនាគារ

### មាត្រា ៤០.. ការផ្អាកប្រតិបត្តិការជាបណ្តោះអាសន្ន

ក្នុងករណីបន្ទាន់ ក្រុមប្រឹក្សានាយកប្រតិបត្តិអាចផ្អាកប្រតិបត្តិការធនាគារជាបណ្តោះអាសន្ន ក្នុងការផ្តល់ឥណទាន ធានា វិនិយោគលើទ្រព្យមូលធន ឬ ទម្រង់ផ្សេងទៀតនៃការផ្តល់ហិរញ្ញប្បទាន ដូចមានចែងក្នុងអនុកថាខណ្ឌ ទី ២ (ចំណុច ៦) នៃមាត្រា ១១ រហូតដល់មានការសម្រេច និងការចាត់វិធានការថ្មី ដោយក្រុមប្រឹក្សាទេសាភិបាល ។



៦៤

**មាត្រា ៤១.. ការបញ្ឈប់ប្រតិបត្តិការ**

១. ធនាគារអាចបញ្ឈប់ប្រតិបត្តិការរបស់ខ្លួន តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល ដែលអនុម័តតាមការបោះឆ្នោតភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

២. បន្ទាប់ពីការបញ្ឈប់ប្រតិបត្តិការ ធនាគារត្រូវបញ្ឈប់រាល់សកម្មភាពទាំងអស់ លើកលែងតែសកម្មភាពពាក់ព័ន្ធនឹងការដោះស្រាយ ការរក្សា និងការពារទ្រព្យសម្បត្តិ ព្រមទាំងការបំពេញកាតព្វកិច្ចនានា របស់ធនាគារ ។

**មាត្រា ៤២.. ការទទួលខុសត្រូវរបស់សមាជិក និងការទូទាត់សង**

១. ក្នុងករណីដែលមានការបញ្ឈប់ប្រតិបត្តិការរបស់ធនាគារ សមាជិកទាំងអស់នៅតែត្រូវបន្តទទួលខុសត្រូវចំពោះភាគហ៊ុនដែលមិនទាន់កោះហៅឱ្យបង់ និងការធ្លាក់ចុះនៃតម្លៃរូបិយវត្ថុរបស់ខ្លួន រហូតដល់ពេលដែលឥណទាយកទាំងអស់ និងកាតព្វកិច្ចជាយថាហេតុនានា ត្រូវបានបំពេញ និងទូទាត់ចប់សព្វគ្រប់ ។

២. ឥណទាយកទាំងអស់ដែលទាមទារការទូទាត់សងផ្ទាល់ពីធនាគារ នឹងត្រូវបានទូទាត់សងចេញពីទ្រព្យសម្បត្តិរបស់ធនាគារ បន្ទាប់មកចេញពីចំណូលរបស់ធនាគារដែលទទួលបានពីការទូទាត់សងនានា ឬ ភាគហ៊ុនមិនទាន់បង់ ឬ ភាគហ៊ុនត្រូវកោះហៅឱ្យបង់ ។ មុននឹងធ្វើការទូទាត់ជូនឥណទាយកណាមួយ ដែលបានទាមទារការទូទាត់សងផ្ទាល់ពីធនាគារ ក្រុមប្រឹក្សានាយកប្រតិបត្តិត្រូវចាត់វិធានការចាំបាច់នានា ដោយផ្អែកលើសុភវនិច្ឆ័យរបស់ខ្លួន ដើម្បីធានានូវការបែងចែកការទូទាត់សងប្រកបដោយសមធម៌រវាងឥណទាយកទាំងអស់ ដែលទាមទារទូទាត់សងដោយផ្ទាល់ និងប្រយោល ។

**មាត្រា ៤៣.. ការបែងចែកទ្រព្យសម្បត្តិ**

១. គ្មានទ្រព្យសម្បត្តិណាមួយរបស់ធនាគារ ត្រូវបានបែងចែកជូនសមាជិកណាមួយចំពោះភាគហ៊ុនដែលខ្លួនបានចូលរួមក្នុងដើមទុនធនាគារបានទេ លុះត្រាតែបន្ទាប់ពី÷

(១) រាល់កាតព្វកិច្ចចំពោះម្ចាស់បំណុលទាំងអស់ ត្រូវបានទូទាត់ចប់សព្វគ្រប់

(២) ទទួលបានការសម្រេចអនុញ្ញាតឱ្យបែងចែកទ្រព្យសម្បត្តិដោយក្រុមប្រឹក្សាទេសាភិបាល ដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

២. រាល់ការបែងចែកទ្រព្យសម្បត្តិរបស់ធនាគារជូនសមាជិក ត្រូវធ្វើឡើងតាមសមាមាត្រនៃភាគហ៊ុនរបស់សមាជិកដែលមាននៅក្នុងដើមទុនរបស់ធនាគារ ហើយត្រូវធ្វើការបែងចែកតាមលក្ខខណ្ឌ និងនៅពេលលាណាមួយដែលធនាគារយល់ថា មានភាពយុត្តិធម៌ និងសមធម៌ ។ ចំណែកនៃទ្រព្យសម្បត្តិដែលត្រូវបែងចែក មិនចាំបាច់ត្រូវតែមានយថាប្រភេទដូចគ្នាទាំងអស់ទេ ។ គ្មានសមាជិកណាមួយ មានសិទ្ធិទទួលបាននូវការបែងចែកទ្រព្យសម្បត្តិពីធនាគារទេ បើសមាជិកនោះនៅមិនទាន់បានបំពេញកាតព្វកិច្ចរបស់ខ្លួនបានរួចរាល់ចំពោះធនាគារ ។

៣. សមាជិកណាមួយដែលបានទទួលទ្រព្យសម្បត្តិបែងចែកក្រោមមាត្រានេះ ត្រូវមានសិទ្ធិលើទ្រព្យសម្បត្តិទាំងនោះ ដូចគ្នានឹងសិទ្ធិដែលធនាគារធ្លាប់មាន នៅមុនពេលត្រូវបានបែងចែក ។

## ជំពូកទី ៩

## បុគ្គលភាព បុព្វសិទ្ធិ អភ័យឯកសិទ្ធិ និងសិទ្ធិទទួលបានការលើកលែង

### មាត្រា ៤៤.. គោលបំណងនៃជំពូកនេះ

១. ដើម្បីផ្តល់លទ្ធភាពឱ្យធនាគារអាចសម្រេចគោលបំណង និងបំពេញមុខងាររបស់ខ្លួនបាន ធនាគារត្រូវទទួលបាននូវ÷ បុគ្គលភាព បុព្វសិទ្ធិ អភ័យឯកសិទ្ធិ និងសិទ្ធិទទួលបានការលើកលែង ដូចបានកំណត់ក្នុងជំពូកនេះ ដែលត្រូវអនុវត្តលើទឹកដីរបស់ប្រទេសជាសមាជិកនីមួយៗ ។

២. សមាជិកនីមួយៗ ត្រូវបំពេញនីតិវិធីចាំបាច់នានាភ្លាម ដើម្បីឱ្យបទប្បញ្ញត្តិខាងលើមានប្រសិទ្ធភាពអនុវត្តជាធរមាននៅលើទឹកដីរបស់ខ្លួន និងត្រូវរាយការណ៍ជូនធនាគារអំពីនីតិវិធីដែលបានបំពេញរួចរាល់ ។

### មាត្រា ៤៥.. បុគ្គលភាពរបស់ធនាគារ

ធនាគារត្រូវមានបុគ្គលភាពគតិយុត្តពេញលេញ និងជាពិសេសត្រូវមានសមត្ថភាពគតិយុត្ត ដូចខាងក្រោម ÷

(១) ចុះកិច្ចសន្យា

(២) ទិញ និងចាត់ចែងលើចលនទ្រព្យ និងអចលនទ្រព្យ

(៣) ប្តឹង ឬ តតាំងបណ្តឹងតាមផ្លូវច្បាប់ និង

(៤) ធ្វើសកម្មភាពនានាផ្សេងទៀតតាមការចាំបាច់ ឬ ដែលមានផលប្រយោជន៍ដល់ការបំពេញមុខងារ និងសម្រេចគោលបំណងរបស់ធនាគារ។

### មាត្រា ៤៦.. អភ័យឯកសិទ្ធិពីបណ្តឹងតាមផ្លូវច្បាប់

១. ធនាគារមានអភ័យឯកសិទ្ធិរួចផុតពីបណ្តឹងតាមផ្លូវច្បាប់នានា លើកលែងតែបណ្តឹងដែលពាក់ព័ន្ធនឹងការអនុវត្តអំណាចរបស់ធនាគារ ក្នុងការកៀរគរធនធានតាមរយៈការខ្ចី ឬ តាមមធ្យោបាយផ្សេងទៀត ការធានាកាតព្វកិច្ច ឬ ការទិញ ការលក់ ឬ ការចុះហត្ថលេខាធានាលើការលក់មូលប័ត្រ ។ ក្នុងគ្រប់ករណីទាំងអស់នេះ បណ្តឹងចំពោះធនាគារត្រូវតែបានធ្វើឡើងនៅតុលាការដែលមានយុត្តាធិការ ក្នុងទឹកដីនៃប្រទេសដែលធនាគារមានការិយាល័យតាំងនៅ ឬ ប្រទេសដែលធនាគារបានចាត់តាំងភ្នាក់ងារឱ្យទទួលការប្រគល់ ឬ ការជូនដំណឹងពីដំណើរការក្តី ឬប្រទេសដែលធនាគារបានបោះផ្សាយមូលប័ត្រ ឬ បានចេញការធានា ។

២. ទោះជាមានបញ្ញត្តិក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ធនាគារមិនអាចត្រូវបានប្តឹងដោយ÷ សមាជិក ទីភ្នាក់ងាររបស់សមាជិក បុគ្គល ឬ ស្ថាប័នពាក់ព័ន្ធផ្សេងទៀតរបស់សមាជិកណាមួយដែលប្តឹងក្នុងនាមសមាជិក ឬ ទីភ្នាក់ងាររបស់សមាជិក ឬ ប្តឹងទៀមទារអ្វីមួយដែលកើតចេញពីសមាជិកឬទីភ្នាក់ងាររបស់សមាជិក ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តីបានឡើយ ។ សមាជិកត្រូវដោះស្រាយនូវវិវាទនានាជាមួយធនាគារ តាមនីតិវិធីដោះស្រាយវិវាទផ្ទៃក្នុងពិសេស រវាងធនាគារ និងសមាជិក ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ វិធាននិងបញ្ញត្តិពាក់ព័ន្ធនានារបស់ធនាគារ ឬ តាមកិច្ចសន្យាដែលបានធ្វើឡើងជាមួយធនាគារ ។

៣. ទ្រព្យសម្បត្តិទាំងអស់របស់ធនាគារ ទោះស្ថិតនៅទីណា និងកាន់កាប់ដោយជនណាក៏ដោយ ត្រូវទទួលបាននូវអភ័យឯកសិទ្ធ ដោយមិនអាចត្រូវបានដកហូត ឃាត់ទុក ឬ អនុវត្តដោយបង្ខំបានឡើយ ដរាបណាសាលក្រមតុលាការប្រឆាំងនឹងធនាគារមិនទាន់ចូលជាស្ថាពរ ។

**មាត្រា ៤៧.. អភ័យឯកសិទ្ធិនៃទ្រព្យសម្បត្តិ និងឯកសារ**

១. ទ្រព្យសម្បត្តិទាំងអស់របស់ធនាគារ ទោះស្ថិតនៅទីណា និងកាន់កាប់ដោយជនណាក៏ដោយ ត្រូវទទួលបាននូវអភ័យឯកសិទ្ធិរួចផុតពីការស្វែងរក ការឃាត់ទុក ការរឹបអូស ការធ្វើអស្សាមិករណ៍ ការដកទុកតាមទម្រង់ណាមួយផ្សេងទៀត ឬ ការដកហូតណាមួយ ដោយសេចក្តីសម្រេចរបស់ស្ថាប័ននីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិ ។

២. រាល់ឯកសារកាលប្បវត្តិ និងឯកសារទូទៅទាំងអស់របស់ធនាគារ ឬ ដែលកាន់កាប់ដោយធនាគារ ត្រូវតែមានភាពមិនអាចរំលោភបំពានបាន ទោះស្ថិតនៅទីណា និងកាន់កាប់ដោយជនណាក៏ដោយ ។

**មាត្រា ៤៨.. ទ្រព្យសម្បត្តិធនាគារមិនត្រូវស្ថិតក្រោមកំហិត**

ដើម្បីឱ្យធនាគារអាចបំពេញមុខងារ និងសម្រេចគោលបំណងរបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព និងដោយស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ រាល់ទ្រព្យសម្បត្តិទាំងអស់របស់ធនាគារ ត្រូវរួចផុតពីរាល់ទម្រង់នៃការរិតត្បិត ការត្រួតពិនិត្យ ឬ ការហាមឃាត់បណ្តោះអាសន្ននានា ។

**មាត្រា ៤៩. បុព្វសិទ្ធិនៃការធ្វើទំនាក់ទំនង**

រាល់ទំនាក់ទំនងជាផ្លូវការរបស់ធនាគារត្រូវតែទទួលបានពីសមាជិកនីមួយៗ នូវប្រព្រឹត្តកម្មដូចគ្នាទៅនឹងអ្វីដែលសមាជិកនោះបានផ្តល់ចំពោះទំនាក់ទំនងជាផ្លូវការជាមួយសមាជិកដ៏ទៃផ្សេងទៀត។

**មាត្រា ៥០.. អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិរបស់មន្ត្រី និងនិយោជិត**

ទេសាភិបាល និងទេសាភិបាលជំនួស នាយកប្រតិបត្តិ និងនាយកប្រតិបត្តិជំនួស ប្រធាន និងអនុប្រធាន និង មន្ត្រី និងនិយោជិតទាំងអស់របស់ធនាគារ ព្រមទាំងជំនាញការ និងទីប្រឹក្សាដែលកំពុងបំពេញភារកិច្ច ឬ បេសកកម្មជូនធនាគារ ÷

(១) ត្រូវទទួលបាននូវអភ័យឯកសិទ្ធិរួចផុតពីបណ្តឹងផ្លូវច្បាប់ចំពោះរាល់កិច្ច ដែលពួកគេបានបំពេញក្នុងសមត្ថភាពផ្លូវការរបស់ពួកគេ លើកលែងតែក្នុងករណីដែលធនាគារបានបោះបង់អភ័យឯកសិទ្ធិទាំងនោះ និងត្រូវទទួលបានភាពមិនអាចរំលោភបំពានបានលើរាល់លិខិត ឯកសារ និងកំណត់ហេតុផ្លូវការនានារបស់ពួកគេ ។

(២) ក្នុងករណីពុំមានសញ្ជាតិនៃប្រទេសដែលខ្លួនកំពុងបម្រើការងារ ត្រូវទទួលបាននូវអភ័យឯកសិទ្ធិរួចផុតពីការរិតត្បិតក្នុងការធ្វើអន្តោប្រវេសន៍ លក្ខខណ្ឌនៃការចុះបញ្ជីអន្តោប្រវេសន៍ និងកាតព្វកិច្ចបម្រើជាតិ ក៏ដូចជាការសម្រួលទាក់ទងនឹងបញ្ញត្តិស្តីពីការប្តូរប្រាក់ ដូចគ្នាទៅនឹងអ្វីដែលរដ្ឋសមាជិកបានផ្តល់ទៅឱ្យអ្នកតំណាង មន្ត្រី និងនិយោជិត ដែលមានឋានៈប្រហាក់ប្រហែល នៃប្រទេសសមាជិកដទៃទៀត ។

(៣) ត្រូវទទួលបាននូវប្រព្រឹត្តកម្មទាក់ទងនឹងការសម្រួលដល់ការធ្វើដំណើរ ដូចគ្នាទៅនឹងប្រព្រឹត្តកម្មដែលសមាជិកបានផ្តល់ទៅឱ្យអ្នកតំណាង មន្ត្រី និង និយោជិត ដែលមានឋានៈប្រហាក់ប្រហែល នៃប្រទេសសមាជិកដទៃទៀត ។

**មាត្រា ៥១.. ការលើកលែងពន្ធ**

១. ធនាគារ ទ្រព្យសម្បត្តិ ចំណូល និងរាល់កិច្ចប្រតិបត្តិការទាំងឡាយរបស់ធនាគារ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានទទួលការលើកលែងពន្ធ និងអាករនានា ។ ធនាគារក៏ត្រូវទទួលបានការលើកលែងពីកាតព្វកិច្ចក្នុងការបង់ ប្រមូល ឬ កាត់ទុកពន្ធ ឬ អាករនានា ។

២. គ្មានពន្ធប្រភេទណាមួយដែលត្រូវប្រមូលយកពាក់ព័ន្ធនឹងប្រាក់បៀវត្សរ៍ ប្រាក់ឈ្នួល ឬ ចំណាយផ្សេងទៀតដែលធនាគារបានបង់ជូននាយកប្រតិបត្តិ នាយកប្រតិបត្តិជំនួស ប្រធាន អនុប្រធាន មន្ត្រី និងបុគ្គលិកផ្សេងទៀតរបស់ធនាគារឡើយ រាប់ទាំងអ្នកជំនាញការនិងទីប្រឹក្សាដែលបំពេញបេសកកម្ម ឬ ផ្តល់សេវាជូនធនាគារ វៀរលែងតែក្នុងករណីដែលសមាជិកណាមួយ បានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រម ដោយបានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ថា សមាជិកនោះ និងស្ថាប័នថ្នាក់ក្រោមជាតិរបស់សមាជិកមួយនោះ រក្សាសិទ្ធិក្នុងការយកពន្ធលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួលដែលបានបង់ដោយធនាគារ ជូនប្រជាពលរដ្ឋដែលមានសញ្ជាតិរបស់ប្រទេសជាសមាជិកនោះ ។

៣. មិនត្រូវជាប់កាតព្វកិច្ចពន្ធ ឬ អាករណាមួយ លើមូលប័ត្រ ឬ សញ្ញាបណ្ណដែលត្រូវបានបោះផ្សាយដោយធនាគារ ដោយរាប់ទាំងភាគលាភ ឬ ការប្រាក់ ទោះបីជាមូលប័ត្រ ឬ សញ្ញាបណ្ណនោះ ត្រូវបានកាន់កាប់ដោយជនណាក៏ដោយ÷

(១) ក្នុងករណីដែលមូលប័ត្រ ឬ សញ្ញាបណ្ណទាំងនោះត្រូវបានបោះផ្សាយទាំងស្រុង ដោយធនាគារ

(២) ក្នុងករណីដែលមូលដ្ឋាននៃការគិតពន្ធត្រូវផ្អែកទាំងស្រុងលើទីកន្លែង ឬ រូបិយប័ណ្ណដែលមូលប័ត្រ ឬ សញ្ញាបណ្ណ ត្រូវបានបោះផ្សាយ តម្រូវឱ្យទូទាត់ ឬ ត្រូវទូទាត់ ឬ ទីតាំងនៃការិយាល័យឬទីកន្លែងធ្វើប្រតិបត្តិការរបស់ធនាគារ

៤. មិនត្រូវជាប់កាតព្វកិច្ចពន្ធ ឬ អាករណាមួយ ដែលកើតចេញពីមូលប័ត្រ ឬ សញ្ញាបណ្ណដែលត្រូវបានធានាដោយធនាគារ រួមទាំងភាគលាភ ឬ ផលប្រយោជន៍នានា ទោះជាត្រូវបានកាន់កាប់ដោយជនណាក៏ដោយ÷

(១) ក្នុងករណីដែលមូលប័ត្រ ឬ សញ្ញាបណ្ណទាំងនោះ ត្រូវបានធានាទាំងស្រុងដោយធនាគារ

(២) ក្នុងករណីដែលមូលដ្ឋាននៃការគិតពន្ធត្រូវផ្អែកទាំងស្រុងលើទីតាំងនៃការិយាល័យ ឬ ទីកន្លែងធ្វើប្រតិបត្តិការណាមួយរបស់ធនាគារ ។

**មាត្រា ៥២.. ការលះបង់**

១. ធនាគារ តាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចលះបង់នូវបុព្វសិទ្ធិ អភ័យឯកសិទ្ធិ ឬ ការទទួលបាននូវការលើកលែងណាមួយ ដែលមានចែងក្នុងជំពូកនេះ ក្នុងករណី ឬ ហេតុផលណាមួយ តាមរបៀប និងលក្ខខណ្ឌដែលកំណត់ដោយធនាគារ និងតាមការចាំបាច់ ដោយត្រូវធ្វើដើម្បីការពារផលប្រយោជន៍ខ្ពស់បំផុតរបស់ធនាគារ ។

## ជំពូកទី ១០

## ការធ្វើវិសោធនកម្ម ការបកស្រាយ និងមជ្ឈត្តកម្ម

**មាត្រា ៥៣.. ការធ្វើវិសោធនកម្ម**

១. កិច្ចព្រមព្រៀងនេះ អាចត្រូវបានធ្វើវិសោធនកម្ម លុះត្រាតែមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាលដែលបានអនុម័តតាមការបោះឆ្នោតដោយមតិភាគច្រើនលើសលប់ ដូចមានចែងក្នុងមាត្រា ២៨ ។

២.  ទោះបីជាបានចែងក្នុងបទប្បញ្ញត្តិក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ក៏ដោយ ការធ្វើវិសោធនកម្ម លើកិច្ចព្រមព្រៀង តម្រូវឱ្យមានការឯកភាពជាឯកច្ឆ័នដោយក្រុមប្រឹក្សាទេសាភិបាល សម្រាប់កែប្រែលើ ÷

(១)  សិទ្ធិក្នុងការដកខ្លួនចេញពីធនាគារ

(២)  ដែនកំណត់នៃការទទួលខុសត្រូវ ដែលមានចែងក្នុងកថាខណ្ឌទី ៣ និងទី ៤ នៃមាត្រា ៧ និង

(៣)  សិទ្ធិពាក់ព័ន្ធនឹងការទិញភាគហ៊ុននៃដើមទុន ដែលមានចែងក្នុងកថាខណ្ឌទី ៤ នៃមាត្រា ៥

៣.  រាល់សំណើសុំធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ទោះជាផ្តើមធ្វើឡើងដោយសមាជិកណាមួយ ឬ ដោយក្រុមប្រឹក្សានាយកប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈប្រធានក្រុមប្រឹក្សាទេសាភិបាល ដើម្បីដាក់សំណើនេះ ជូនក្រុម-ប្រឹក្សាទេសាភិបាល ពិនិត្យ និង សម្រេច ។ ក្រោយពេលដែលវិសោធនកម្មត្រូវបានអនុម័ត ធនាគារត្រូវផ្តល់ការបញ្ជាក់អំពីការធ្វើវិសោធនកម្មនេះ តាមរយៈការជូនដំណឹងជាផ្លូវការដល់សមាជិកទាំងអស់ ។ ការធ្វើវិសោធនកម្មត្រូវចូលជាធរមាន ក្នុងរយៈពេល ៣ ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងជាផ្លូវការ លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយក្រុមប្រឹក្សាទេសាភិបាល ។

**មាត្រា ៥៤.. ការបកស្រាយ**

១.  ក្នុងករណីដែលមានបញ្ហាត្រូវធ្វើការបកស្រាយ ឬ ក្នុងការអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលកើតឡើងរវាងសមាជិកណាមួយជាមួយធនាគារ ឬ រវាងសមាជិកពីរ ឬ ច្រើនរបស់ធនាគារ បញ្ហាទាំងនោះ ត្រូវដាក់ជូនក្រុមប្រឹក្សានាយកប្រតិបត្តិធ្វើការសម្រេច ។ ក្នុងករណីសមាជិកណាមួយដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះ ពុំមាននាយកប្រតិបត្តិជាសញ្ជាតិរបស់ប្រទេសខ្លួនក្នុងក្រុមប្រឹក្សានាយកប្រតិបត្តិទេ សមាជិកនោះមានសិទ្ធិចាត់តាំងអ្នកតំណាងរបស់ខ្លួន ឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សានាយកប្រតិបត្តិ ប៉ុន្តែអ្នកតំណាងនោះពុំមានសិទ្ធិបោះឆ្នោតទេ ។ សិទ្ធិជាអ្នកតំណាងនេះ នឹងត្រូវកំណត់ដោយក្រុមប្រឹក្សាទេសាភិបាល ។

២.  បន្ទាប់ពីក្រុមប្រឹក្សានាយកប្រតិបត្តិបានធ្វើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះរួចហើយ បើនៅមានសមាជិកណាមួយមិនសុខចិត្ត សមាជិកនោះអាចបន្តប្តឹងទៅក្រុមប្រឹក្សាទេសាភិបាល ដើម្បីពិនិត្យ និងសម្រេចជាចុងក្រោយ ។ ក្នុងរយៈពេលរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល ក្នុងករណីចាំបាច់ ធនាគារអាចអនុវត្តដោយផ្អែកលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានាយកប្រតិបត្តិ ។

**មាត្រា ៥៥.. មជ្ឈត្តកម្ម**

ក្នុងករណីដែលមានបញ្ហាមិនចុះសម្រុងគ្នា រវាងធនាគារជាមួយនឹងប្រទេសដែលត្រូវបញ្ចប់សមាជិកភាព ឬ រវាងធនាគារជាមួយនឹងសមាជិកណាមួយ ក្រោយពីធនាគារបានអនុម័តសម្រេចបញ្ឈប់ប្រតិបត្តិការរបស់ធនាគារ បញ្ហាមិនចុះសម្រុងគ្នាទាំងនេះ ត្រូវដោះស្រាយតាមរយៈមជ្ឈត្តកម្ម ដែលត្រូវមានសមាសភាពមជ្ឈត្តករចំនួន ៣ រូប ។ មជ្ឈត្តករមួយរូបត្រូវតែងតាំងដោយធនាគារ មជ្ឈត្តករមួយរូបទៀតត្រូវតែងតាំងដោយប្រទេសដែលជាគូភាគី ហើយមជ្ឈត្តករទី ៣ ត្រូវតែងតាំងដោយប្រធានតុលាការយុត្តិធម៌អន្តរជាតិ ឬ ស្ថាប័នប្រហាក់ប្រហែលផ្សេងទៀត ដូចមានចែងក្នុងវិធានដែលអនុម័តដោយក្រុមប្រឹក្សាទេសាភិបាល លើកលែងតែមានការព្រមព្រៀងដោយឡែករបស់គូភាគី។

ការសម្រេចរបស់មជ្ឈត្តករ ត្រូវធ្វើឡើងតាមការបោះឆ្នោតដោយមតិភាគច្រើន ដែលជាសេចក្តីសម្រេចបិទផ្លូវតវ៉ា និងមានអានុភាពចាប់បង្ខំឱ្យអនុវត្តចំពោះគូភាគី។ មជ្ឈត្តករទី ៣ ត្រូវមានអំណាចក្នុងការដោះស្រាយលើរាល់បញ្ហានៃនីតិវិធីទាំងឡាយ ដែលគូភាគីមិនចុះសម្រុងជាមួយគ្នា ។

**មាត្រា ៥៦.. ការសន្មតថាបានផ្តល់ការអនុម័តយល់ព្រម**

ក្នុងករណីដែលតម្រូវឱ្យមានការអនុម័តយល់ព្រមជាមុនដោយសមាជិកណាមួយ មុននឹងមានការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិណាមួយដោយធនាគារ លើកលែងតែករណីដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ៥៣ ខាងលើ ត្រូវបានចាត់ទុកថា បទប្បញ្ញត្តិនោះបានទទួល នូវការអនុម័តយល់ព្រមដោយសមាជិកនោះ វៀរលែងតែមានសមាជិកណាមួយ បានបង្ហាញការជំទាស់របស់ខ្លួនក្នុងរយៈពេលមួយដែលកំណត់ដោយធនាគារនៅក្នុងលិខិតជូនដំណឹងអំពីបទបញ្ញត្តិដែលបានស្នើ ។

## ជំពូកទី ១១

## អវសានបញ្ញត្តិ

**មាត្រា ៥៧.. ការចុះហត្ថលេខា និងការតម្កល់ទុក**

១. កិច្ចព្រមព្រៀងនេះ ត្រូវបានតម្កល់ទុកដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដែលតាមនេះហៅថា "ស្ថាប័នតម្កល់" ហើយកិច្ចព្រមព្រៀងនេះ នៅតែបន្តបើកចំហរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សម្រាប់ការចុះហត្ថលេខាចូលជាសមាជិក ដោយបណ្តារដ្ឋាភិបាលនៃប្រទេស ដូចមានរាយឈ្មោះក្នុងឧបសម្ព័ន្ធ "ក" ។

២. ស្ថាប័នតម្កល់ត្រូវផ្ញើកិច្ចព្រមព្រៀងដែលមានបញ្ជាក់ថាថតចម្លងចេញពីច្បាប់ដើម ជូនរាល់ប្រទេសជាហត្ថលេខី និងប្រទេសនានាដែលបានក្លាយជាសមាជិករបស់ធនាគារ ។

**មាត្រា ៥៨.. ការធ្វើសច្ចាប័ន ការទទួលយក និងការអនុម័តយល់ព្រម**

១. កិច្ចព្រមព្រៀងនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រមដោយប្រទេសជាហត្ថលេខី ។ លិខិតុបករណ៍ នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រម ត្រូវតម្កល់ទុកនៅកន្លែងស្ថាប័នតម្កល់ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ឬ ក្នុងករណីចាំបាច់ អាចតម្កល់នៅក្រោយកាលបរិច្ឆេទនេះ តាមការសម្រេចរបស់ក្រុមប្រឹក្សាទេសាភិបាល ដោយមតិភាគច្រើនពិសេស ដូចមានចែងក្នុងមាត្រា ២៨ ។ ស្ថាប័នតម្កល់ត្រូវជូនដំណឹងដល់ប្រទេសជាហត្ថលេខីទាំងអស់ អំពីការតម្កល់ និងកាលបរិច្ឆេទនៃការតម្កល់នីមួយៗ ។

២. ប្រទេសជាហត្ថលេខីណាមួយដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រម មុនកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវក្លាយជាសមាជិករបស់ធនាគារនៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមាន ។ ប្រទេសជាហត្ថលេខីផ្សេងទៀត ដែលបានបំពេញនីតិវិធីស្របតាមបទប្បញ្ញត្តិនៃកថាខណ្ឌខាងលើ ត្រូវក្លាយជាសមាជិករបស់ធនាគារ នៅកាលបរិច្ឆេទដែលបានតម្កល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រម ។

**មាត្រា ៥៩.- ការចូលជាធរមាន**

កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន នៅពេលដែលលិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ឬ ការអនុម័តយល់ព្រម ត្រូវបានតម្កល់ដោយប្រទេសជាហត្ថលេខីយ៉ាងតិចចំនួន ១០ និងដែលជាប្រទេសមាន ភាគហ៊ុនដំបូងសរុបមិនតិចជាង ៥០% នៃភាគហ៊ុនដំបូងសរុប ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ “ក” ។

**មាត្រា ៦០.- កិច្ចប្រជុំជាផ្លូវការដំបូង និងចាប់ផ្តើមកិច្ចប្រតិបត្តិការ**

១. បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមានភ្លាម សមាជិកនីមួយៗ ត្រូវចាត់តាំងទេសាភិបាលមួយរូប ហើយស្ថាប័នតម្កល់ត្រូវកោះហៅប្រជុំជាផ្លូវការលើកដំបូងរបស់ក្រុមប្រឹក្សាទេសាភិបាល ។

២. ក្នុងកិច្ចប្រជុំជាផ្លូវការលើកដំបូង ក្រុមប្រឹក្សាទេសាភិបាល ÷

(១) ត្រូវបោះឆ្នោតជ្រើសតាំងប្រធានធនាគារ

(២) ត្រូវបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិរបស់ធនាគារ ស្របតាមកថាខណ្ឌទី ១ នៃមាត្រា ២៥ ប៉ុន្តែ ក្រុមប្រឹក្សាទេសាភិបាល អាចបោះឆ្នោតសម្រេចយកនាយកប្រតិបត្តិ តិចជាង ១២ រូបបាន សម្រាប់រយៈពេលចាប់ផ្តើមដំបូងនៃកិច្ចប្រតិបត្តិការរបស់ធនាគារ ដែលរយៈពេលនេះមិនត្រូវលើស ២ ឆ្នាំ ដោយអាស្រ័យទៅតាមចំនួនសមាជិក និងប្រទេសជាហត្ថលេខីនានា ដែលមិនទាន់ក្លាយជាសមាជិក

(៣) ត្រូវចាត់ចែងលើការកំណត់កាលបរិច្ឆេទសម្រាប់ការចាប់ផ្តើមកិច្ចប្រតិបត្តិការរបស់ធនាគារ

(៤) ត្រូវចាត់ចែងកិច្ចការនានាផ្សេងទៀត តាមការចាំបាច់ សម្រាប់ការចាប់ផ្តើមកិច្ចប្រតិបត្តិការរបស់ធនាគារ

៣. ធនាគារត្រូវជូនដំណឹងដល់សមាជិកទាំងអស់ អំពីកាលបរិច្ឆេទនៃការចាប់ផ្តើមកិច្ចប្រតិបត្តិការរបស់ធនាគារ ។

បានធ្វើនៅរដ្ឋធានីប៉េកាំង សាធារណរដ្ឋប្រជាមានិតចិន នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ជាច្បាប់ដើមចំនួន ០១ ច្បាប់ ដែលត្រូវបានតម្កល់ទុកនៅបណ្ណាសាររបស់ស្ថាប័នតម្កល់ និងត្រូវបានធ្វើជាភាសាអង់គ្លេស ចិន និងបារាំង ដែលមានតម្លៃស្មើគ្នា ។



ស

**ឧបសម្ព័ន្ធ "ក"**

ការចុះឈ្មោះទិញភាគហ៊ុនដំបូងនៃដើមទុនសម្រាប់ប្រទេសដែលអាចក្លាយជាសមាជិក

អនុលោមតាមមាត្រា ៥៨

| | ចំនួនភាគហ៊ុន | តម្លៃភាគហ៊ុន (លានដុល្លារអាមេរិក) |
|---|---|---|
| **ផ្នែក "ក"** | | |
| សមាជិកក្នុងតំបន់ | | |
| អូស្ត្រាលី | ៣៦ ៩១២ | ៣ ៦៩១,២ |
| អាស៊ែបៃហ្សង់ | ២ ៥៤១ | ២៥៤,១ |
| បង់ក្លាដែស | ៦ ៦០៥ | ៦៦០,៥ |
| ព្រុយណេ | ៥២៤ | ៥២,៤ |
| កម្ពុជា | ៦២៣ | ៦២,៣ |
| ចិន | ២៩៧ ៨០៤ | ២៩ ៧៨០,៤ |
| ហ្សកហ្ស៊ី | ៥៣៩ | ៥៣,៩ |
| ឥណ្ឌា | ៨៣ ៦៧៣ | ៨ ៣៦៧,៣ |
| ឥណ្ឌូណេស៊ី | ៣៣ ៦០៧ | ៣ ៣៦០,៧ |
| អ៊ីរ៉ង់ | ១៥ ៨០៨ | ១ ៥៨០,៨ |
| អ៊ីស្រាអែល | ៧ ៤៩៩ | ៧៤៩,៩ |
| ហ្ស៊កដានី | ១ ១៩២ | ១១៩,២ |
| កាហ្សាក់ស្ថាន | ៧ ២៩៣ | ៧២៩,៣ |
| កូរ៉េខាងត្បូង | ៣៧ ៣៨៨ | ៣ ៧៣៨,៨ |
| កូវ៉ែត | ៥ ៣៦០ | ៥៣៦,០ |
| កៀហ្ស៊ីស៊ីស្ថាន | ២៦៨ | ២៦,៨ |
| ឡាវ | ៤៣០ | ៤៣,០ |
| ម៉ាឡេស៊ី | ១ ០៩៥ | ១០៩,៥ |
| ម៉ាល់ឌីវ | ៧២ | ៧,២ |
| ម៉ុងហ្គោលី | ៤១១ | ៤១,១ |
| មីយ៉ាន់ម៉ា | ២ ៦៤៥ | ២៦៤,៥ |
| នេប៉ាល់ | ៨០៩ | ៨០,៩ |
| នូវែលសេឡង់ | ៤ ៦១៥ | ៤៦១,៥ |

| | | |
|---|---|---|
| អូម៉ង់ | ២ ៥៩២ | ២៥៩,២ |
| ប៉ាគីស្ថាន | ១០ ៣៤១ | ១ ០៣៤,១ |
| ហ្វីលីពីន | ៩ ៧៩១ | ៩៧៩,១ |
| កាតា | ៦ ០៤៤ | ៦០៤,៤ |
| រុស្ស៊ី | ៦៥ ៣៦២ | ៦ ៥៣៦,២ |
| អារ៉ាប៊ីសាអូឌីត | ២៥ ៤៤៦ | ២ ៥៤៤,៦ |
| សិង្ហបុរី | ២ ៥០០ | ២៥០,០ |
| ស្រីលង្កា | ២ ៦៩០ | ២៦៩,០ |
| តាហ្ស៊ីគីស្ថាន | ៣០៩ | ៣០,៩ |
| ថៃ | ១៤ ២៧៥ | ១ ៤២៧,៥ |
| តួកគី | ២៦ ០៩៩ | ២ ៦០៩,៩ |
| អេមីរ៉ាតអារ៉ាប់រួម | ១១ ៨៥៧ | ១ ១៨៥,៧ |
| អ៊ូសបេគីស្ថាន | ២ ១៩៨ | ២១៩,៨ |
| វៀតណាម | ៦ ៦៣៣ | ៦៦៣,៣ |
| ភាគហ៊ុនមិនទាន់បែងចែក | ១៦ ១៥០ | ១ ៦១៥,០ |
| សរុប | ៧៥០ ០០០ | ៧៥ ០០០,០ |

**ផ្នែក "ខ"**

សមាជិកក្រៅតំបន់

| | | |
|---|---|---|
| អូទ្រីស | ៥ ០០៨ | ៥០០,៨ |
| ប្រេស៊ីល | ៣១ ៨១០ | ៣ ១៨១,០ |
| ដាណឺម៉ាក | ៣ ៦៩៥ | ៣៦៩,៥ |
| អេហ្ស៊ីប | ៦ ៥០៥ | ៦៥០,៥ |
| ហ្វាំងឡង់ | ៣ ១០៣ | ៣១០,៣ |
| បារាំង | ៣៣ ៧៥៦ | ៣ ៣៧៥,៦ |
| អាល្លឺម៉ង់ | ៤៤ ៨៤២ | ៤ ៤៨៤,២ |
| អ៊ីស្លង់ | ១៧៦ | ១៧,៦ |
| អ៊ីតាលី | ២៥ ៧១៨ | ២ ៥៧១,៨ |
| លុចសំបួ | ៦៩៧ | ៦៩,៧ |
| ម៉ាល់ត៍ | ១៣៦ | ១៣,៦ |
| ហូឡង់ | ១០ ៣១៣ | ១ ០៣១,៣ |

| | | |
|---|---|---|
| ន័រវែស | ៥ ៥០៦ | ៥៥០,៦ |
| ប៉ូឡូញ | ៨ ៣១៨ | ៨៣១,៨ |
| ព័រទុយហ្គាល់ | ៦៥០ | ៦៥,០ |
| អាហ្វ្រិកខាងត្បូង | ៥ ៩០៥ | ៥៩០,៥ |
| អេស្ប៉ាញ | ១៧ ៦១៥ | ១ ៧៦១,៥ |
| ស៊ុយអែត | ៦ ៣០០ | ៦៣០,០ |
| ស្វ៊ីស | ៧ ០៦៤ | ៧០៦,៤ |
| អង់គ្លេស | ៣០ ៥៤៧ | ៣ ០៥៤,៧ |
| ភាគហ៊ុនមិនទាន់បែងចែក | ២ ៣៣៦ | ២៣៣,៦ |
| សរុបរង | ២៥០ ០០០ | ២៥ ០០០,០ |
| **សរុប** | ១ ០០០ ០០០ | ១០០ ០០០,០ |

## ឧបសម្ព័ន្ធ "ខ"

## ការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិ

ក្រុមប្រឹក្សាទេសាភិបាល ត្រូវកំណត់វិធានសម្រាប់រៀបចំការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិនីមួយៗ ដោយត្រូវអនុលោមតាមបទប្បញ្ញត្តិ ដូចខាងក្រោម៖

១. ការិយាល័យតំណាង៖ នាយកប្រតិបត្តិនីមួយៗ ត្រូវតំណាងឱ្យសមាជិក ១ ឬ ច្រើនរូប ក្នុងការិយាល័យតំណាង ។ ចំនួនសរុបនៃសិទ្ធិបោះឆ្នោតរបស់ការិយាល័យតំណាងនីមួយៗ ត្រូវស្មើនឹងចំនួនសរុបនៃសិទ្ធិបោះឆ្នោតដែលនាយកប្រតិបត្តិ មានដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រា ២៨ ។

២. សិទ្ធិបោះឆ្នោតរបស់ការិយាល័យតំណាង៖ ក្នុងការបោះឆ្នោតនីមួយៗ ក្រុមប្រឹក្សាទេសាភិបាលត្រូវកំណត់នូវភាគរយអប្បបរមានៃសិទ្ធិបោះឆ្នោតសម្រាប់ការិយាល័យតំណាងរបស់នាយកប្រតិបត្តិ ដែលត្រូវបោះឆ្នោតជ្រើស-តាំងដោយទេសាភិបាលដែលតំណាងសមាជិកក្នុងតំបន់ (នាយកប្រតិបត្តិក្នុងតំបន់) និងភាគរយអប្បបរមានៃសិទ្ធិបោះឆ្នោតសម្រាប់ការិយាល័យតំណាងរបស់នាយកប្រតិបត្តិ ដែលត្រូវបោះឆ្នោតដោយទេសាភិបាល ដែលតំណាងសមាជិកក្រៅតំបន់ (នាយកប្រតិបត្តិក្រៅតំបន់) ។

ក. ភាគរយអប្បបរមាសម្រាប់នាយកប្រតិបត្តិក្នុងតំបន់ ត្រូវកំណត់ជាភាគរយនៃសិទ្ធិបោះឆ្នោតសរុបដែលអាចបោះឆ្នោតបាន ដោយទេសាភិបាលដែលតំណាងសមាជិកក្នុងតំបន់ (ទេសាភិបាលក្នុងតំបន់) ។ ភាគរយអប្បបរមាដំបូងសម្រាប់នាយកប្រតិបត្តិក្នុងតំបន់ត្រូវមានចំនួន ៦% ។

ខ. ភាគរយអប្បបរមាសម្រាប់នាយកប្រតិបត្តិក្រៅតំបន់ ត្រូវកំណត់ជាភាគរយនៃសិទ្ធិបោះឆ្នោតសរុបដែលអាចបោះឆ្នោតបាន ដោយទេសាភិបាលដែលតំណាងសមាជិកក្រៅតំបន់ (ទេសាភិបាលក្រៅតំបន់) ។ ភាគរយអប្បបរមាដំបូងសម្រាប់នាយកប្រតិបត្តិក្រៅតំបន់ត្រូវមានចំនួន ១៥% ។

៣. ការកែតម្រូវភាគរយ៖ ដើម្បីកែតម្រូវសិទ្ធិបោះឆ្នោតឆ្លងការិយាល័យតំណាង នៅពេលដែលមានការបោះឆ្នោតនៅជុំបន្តបន្ទាប់ ដូចបានកំណត់ក្នុងកថាខណ្ឌទី ៧ ខាងក្រោម ក្រុមប្រឹក្សាទេសាភិបាល ត្រូវធ្វើការកែតម្រូវភាគរយសម្រាប់នាយកប្រតិបត្តិក្នុងតំបន់ និងនាយកប្រតិបត្តិក្រៅតំបន់ នៅរៀងរាល់ជុំបោះឆ្នោតនីមួយៗ ។ ការកែតម្រូវភាគរយនីមួយៗ ត្រូវតែមានតម្រិតខ្ពស់ជាងភាគរយអប្បបរមា ។

ក. ការកែតម្រូវភាគរយសម្រាប់នាយកប្រតិបត្តិក្នុងតំបន់ ត្រូវកំណត់ជាភាគរយនៃសិទ្ធិបោះឆ្នោតសរុបដែលអាចបោះឆ្នោតបាន ដោយទេសាភិបាលដែលតំណាងសមាជិកក្នុងតំបន់ (ទេសាភិបាលក្នុងតំបន់) ។ ភាគរយកែតម្រូវដំបូងសម្រាប់នាយកប្រតិបត្តិក្នុងតំបន់ត្រូវមានចំនួន ១៥% ។

ខ. ភាគរយកែតម្រូវសម្រាប់នាយកប្រតិបត្តិក្រៅតំបន់ ត្រូវកំណត់ជាភាគរយនៃសិទ្ធិបោះឆ្នោតសរុបដែលអាចបោះឆ្នោតបាន ដោយទេសាភិបាលដែលតំណាងសមាជិកក្រៅតំបន់ (ទេសាភិបាលក្រៅតំបន់) ។ ភាគរយកែតម្រូវដំបូងសម្រាប់នាយកប្រតិបត្តិក្រៅតំបន់ត្រូវមានចំនួន ៦០% ។

៤. ចំនួនបេក្ខជន៖ ក្នុងការបោះឆ្នោតនីមួយៗ ក្រុមប្រឹក្សាទេសាភិបាលត្រូវកំណត់ចំនួននាយកប្រតិបត្តិក្នុងតំបន់ និងនាយកប្រតិបត្តិក្រៅតំបន់ ដែលត្រូវបោះឆ្នោតជ្រើសតាំង ។ ការសម្រេចចិត្តលើចំនួន និងសមាសភាពនៃក្រុមប្រឹក្សានាយកប្រតិបត្តិ ត្រូវស្របតាមកថាខណ្ឌទី ២ នៃមាត្រា ២៥ ។

ក. ចំនួនដំបូងនៃនាយកប្រតិបត្តិក្នុងតំបន់ ត្រូវមាន ៩ រូប ។

ខ. ចំនួនដំបូងនៃនាយកប្រតិបត្តិក្រៅតំបន់ ត្រូវមាន ៣ រូប ។

៥. ការចាត់តាំង÷ ទេសាភិបាលនីមួយៗ អាចចាត់តាំងបេក្ខជនតែមួយរូបគត់ ។ បេក្ខជនសម្រាប់តំណែងនាយកប្រតិបត្តិក្នុងតំបន់ ត្រូវចាត់តាំងដោយទេសាភិបាលក្នុងតំបន់។ បេក្ខជនសម្រាប់តំណែងនាយកប្រតិបត្តិក្រៅតំបន់ ត្រូវចាត់តាំងដោយទេសាភិបាលក្រៅតំបន់ ។

៦. ការបោះឆ្នោត÷ ទេសាភិបាលនីមួយៗ អាចបោះឆ្នោតជូនបេក្ខជនតែមួយរូបប៉ុណ្ណោះ ដែលសម្លេងបោះឆ្នោតរបស់សមាជិកនីមួយៗត្រូវគិតតាមមូលដ្ឋានដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ២៨ ។ ការបោះឆ្នោតជ្រើស-តាំងនាយកប្រតិបត្តិក្នុងតំបន់ ត្រូវធ្វើឡើងដោយទេសាភិបាលក្នុងតំបន់ ។ ការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិក្រៅតំបន់ ត្រូវធ្វើឡើងដោយទេសាភិបាលក្រៅតំបន់ ។

៧. ការបោះឆ្នោតជុំទី ១ ÷ ក្នុងការបោះឆ្នោតជុំទី ១ បេក្ខជនដែលទទួលបានសម្លេងបោះឆ្នោតគាំទ្រច្រើនជាងគេត្រូវជាប់ឆ្នោតជានាយកប្រតិបត្តិ ដោយត្រូវជ្រើសយកតាមលំដាប់លេខរៀងជាបន្តបន្ទាប់ រហូតដល់គ្រប់ចំនួននាយកប្រតិបត្តិដែលត្រូវជ្រើសរើស និងចាំបាច់ត្រូវតែទទួលបានសម្លេងបោះឆ្នោតមិនតិចជាងចំនួនភាគរយអប្បបរមាដូចដែលបានកំណត់ ។

ក្នុងករណីដែលការបោះឆ្នោតជុំទី ១ មិនអាចជ្រើសរើសនាយកប្រតិបត្តិបានគ្រប់ចំនួន ហើយបើចំនួនបេក្ខជននៅសល់មានចំនួនស្មើនឹងចំនួននាយកប្រតិបត្តិដែលត្រូវបន្តជ្រើសរើស ទេសាភិបាលត្រូវដាក់ចេញនូវវិធានការបន្ទាប់ ដើម្បីបញ្ចប់ជាស្ថាពរនូវដំណើរការបោះឆ្នោតជ្រើសរើសនាយកប្រតិបត្តិក្នុងតំបន់ ឬ ក្រៅតំបន់ ។

៨. ការបោះឆ្នោតជុំបន្តបន្ទាប់÷ ក្នុងករណីដែលមិនអាចជ្រើសរើសនាយកប្រតិបត្តិបានគ្រប់ចំនួននៅជុំទី ១ និង នៅសល់បេក្ខជនច្រើនជាងចំនួននាយកប្រតិបត្តិដែលត្រូវបន្តជ្រើសរើស ចាំបាច់ត្រូវរៀបចំធ្វើការបោះឆ្នោតនៅជុំបន្ទាប់ ដូចខាងក្រោម÷

ក. បេក្ខជនណាមួយដែលទទួលបានសម្លេងបោះឆ្នោតតិចជាងគេបំផុត នៅក្នុងការបោះឆ្នោតជុំលើកមុន មិនអាចបន្តឈរឈ្មោះបោះឆ្នោត នៅជុំបន្ទាប់ទៀតបានទេ ។

ខ. ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដោយ÷ (១) ទេសាភិបាលដែលបានបោះឆ្នោតជូនបេក្ខជនដែលមិនបានជាប់ឆ្នោតនៅជុំលើកមុន និង (២) ទេសាភិបាលដែលបានបោះឆ្នោតជូនបេក្ខជនដែលជាប់ឆ្នោត តែនៅចាំបាច់ត្រូវការបង្កើនសម្លេងបន្ថែម ដើម្បីឱ្យសម្លេងឆ្នោតលើសពីភាគរយអប្បបរមាកែតម្រូវ ដូចមានចែងក្នុងចំណុច “គ” ខាងក្រោម ។

គ. សម្លេងឆ្នោតរបស់ទេសាភិបាលទាំងអស់ដែលបានបោះឆ្នោតគាំទ្របេក្ខជននីមួយៗ នឹងត្រូវបានបន្ថែមសម្លេងតាមលំដាប់លេខរៀងនៃចំនួនពីខ្ពស់មកទាប រហូតដល់មានចំនួនលើសពីភាគរយអប្បបរមាកែតម្រូវ ។ ទេសាភិបាលណា ដែលសម្លេងឆ្នោតរបស់ខ្លួន ត្រូវបានរាប់បញ្ចូលបន្ថែមទៅក្នុងចំនួនសម្លេងឆ្នោតគាំទ្រនាយកប្រតិបត្តិរូបណាមួយក្នុងការគណនាខាងលើ ត្រូវចាត់ទុកថាបានបោះឆ្នោតគាំទ្រនាយកប្រតិបត្តិរូបនោះ និងដោយរាប់ទាំងសម្លេងឆ្នោតរបស់ទេសាភិបាល

ដែលត្រូវបានរាប់បញ្ចូល ដើម្បីឱ្យលើសភាគរយអប្បបរមាផងដែរ ។ ទេសាភិបាលផ្សេងពីនេះដែលសម្លេងឆ្នោតមិនត្រូវបាន រាប់បញ្ចូលក្នុងការគណនាខាងលើ ត្រូវចាត់ទុកថា មិនបានបោះឆ្នោតជូនបេក្ខជនរូបនោះទេ ហើយទេសាភិបាលនោះ អាចបន្តទៅបោះឆ្នោតនៅជុំបន្ទាប់ទៀតបាន ។

ឃ. ក្នុងករណីដែលនៅជុំបន្ទាប់ នៅសល់នាយកប្រតិបត្តិតែមួយរូបដែលត្រូវបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិនោះ អាចត្រូវបានបោះឆ្នោតដោយយកសម្លេងភាគច្រើននៃសម្លេងឆ្នោតដែលនៅសល់ ។ សម្លេងឆ្នោតដែលនៅសល់នេះ ត្រូវបានចាត់ទុកថាបានបោះឆ្នោតជូននាយកប្រតិបត្តិចុងក្រោយទាំងអស់ ។

៩. ការចាត់តាំងសម្លេងបោះឆ្នោត÷ ក្នុងករណីដែលទេសាភិបាលណាមួយ មិនបានចូលរួមក្នុងដំណើរការបោះឆ្នោត ឬ សម្លេងឆ្នោតរបស់ទេសាភិបាលនោះ មិនអាចរួមចំណែកដល់ការជ្រើសតាំងនាយកប្រតិបត្តិណាមួយបាន ទេសាភិបាលនោះ អាចចាត់តាំងសម្លេងឆ្នោតរបស់ខ្លួនឱ្យតំណាងដោយនាយកប្រតិបត្តិជាប់ឆ្នោតរូបណាមួយបាន ប៉ុន្តែត្រូវមានការព្រមព្រៀងជាមុនពីទេសាភិបាលដទៃផ្សេងទៀតដែលបានជ្រើសតាំងនាយកប្រតិបត្តិរូបនោះ ។

១០. បុព្វសិទ្ធិរបស់សមាជិកស្ថាបនិក÷ ការចាត់តាំង និងការបោះឆ្នោតជ្រើសតាំងនាយកប្រតិបត្តិដោយទេសាភិបាល និងការតែងតាំងនាយកប្រតិបត្តិជំនួសដោយនាយកប្រតិបត្តិ ត្រូវធ្វើឡើងដោយគោរពគោលការណ៍ដែលថាសមាជិកស្ថាបនិកនីមួយៗ មានបុព្វសិទ្ធិក្នុងការចាត់តាំងនាយកប្រតិបត្តិ ឬ នាយកប្រតិបត្តិជំនួស នៅក្នុងការិយាល័យតំណាងរបស់ខ្លួន ជាប្រចាំ ឬ តាមការប្តូរវេន ។

# Asian Infrastructure Investment Bank
# Articles of Agreement

# 亚洲基础设施投资银行协定

# Statuts
# de la Banque Asiatique d'Investissement
# dans les Infrastructures

# Asian Infrastructure Investment Bank

# Articles of Agreement

**The countries on whose behalf the present Agreement is signed agree as follows:**

**CONSIDERING** the importance of regional cooperation to sustain growth and promote economic and social development of the economies in Asia and thereby contribute to regional resilience against potential financial crises and other external shocks in the context of globalization;

**ACKNOWLEDGING** the significance of infrastructure development in expanding regional connectivity and improving regional integration, thereby promoting economic growth and sustaining social development for the people in Asia, and contributing to global economic dynamism;

**REALIZING** that the considerable long-term need for financing infrastructure development in Asia will be met more adequately by a partnership among existing multilateral development banks and the Asian Infrastructure Investment Bank (hereinafter referred to as the "Bank");

**CONVINCED** that the establishment of the Bank as a multilateral financial institution focused on infrastructure development will help to mobilize much needed additional resources from inside and outside Asia and to remove the financing bottlenecks faced by the individual economies in Asia, and will complement the existing multilateral development banks, to promote sustained and stable growth in Asia;

**HAVE AGREED** to establish the Bank, which shall operate in accordance with the following:

## Chapter I

## PURPOSE, FUNCTIONS AND MEMBERSHIP

### Article 1 Purpose

1. The purpose of the Bank shall be to: (i) foster sustainable economic development, create wealth and improve infrastructure connectivity in Asia by investing in infrastructure and other productive sectors; and (ii) promote regional cooperation and partnership in addressing development challenges by working in close collaboration with other multilateral and bilateral development institutions.

2. Wherever used in this Agreement, references to "Asia" and "region" shall include the geographical regions and composition classified as Asia and Oceania by the United Nations, except as otherwise decided by the Board of Governors.

### Article 2 Functions

To implement its purpose, the Bank shall have the following functions:

(i) to promote investment in the region of public and private capital for development purposes, in particular for development of infrastructure and other productive sectors;

(ii) to utilize the resources at its disposal for financing such development in the region, including those projects and programs which will contribute most effectively to the harmonious economic growth of the region as a whole and having special regard to the needs of less developed members in the region;

(iii) to encourage private investment in projects, enterprises and activities contributing to economic development in the region, in particular in infrastructure and other productive sectors, and to supplement private investment when private capital is not available on reasonable terms and conditions; and

(iv) to undertake such other activities and provide such other services as may further these functions.

### Article 3 Membership

1. Membership in the Bank shall be open to members of the International Bank for Reconstruction and Development or the Asian Development Bank.

(a) Regional members shall be those members listed in Part A of Schedule A and other members included in the Asia region in accordance with paragraph 2 of Article 1. All other members shall be non-regional members.

(b) Founding Members shall be those members listed in Schedule A which, on or before the date specified in Article 57, shall have signed this Agreement and shall have fulfilled all other conditions of membership before the final date specified under paragraph 1 of Article 58.

2. Members of the International Bank for Reconstruction and Development or the Asian Development Bank which do not become members in accordance with Article 58 may be admitted, under such terms and conditions as the Bank shall determine, to membership in the Bank by a Special Majority vote of the Board of Governors as provided in Article 28.

3. In the case of an applicant which is not sovereign or not responsible for the conduct of its international relations, application for membership in the Bank shall be presented or agreed by the member of the Bank responsible for its international relations.

## CHAPTER II

## CAPITAL

### Article 4 Authorized Capital

1. The authorized capital stock of the Bank shall be one hundred billion United States dollars ($100,000,000,000), divided into one million (1,000,000) shares having a par value of 100,000 dollars ($100,000) each, which shall be available for subscription only by members in accordance with the provisions of Article 5.

2. The original authorized capital stock shall be divided into paid-in shares and callable shares. Shares having an aggregate par value of twenty billion dollars ($20,000,000,000) shall be paid-in shares, and shares having an aggregate par value of eighty billion dollars ($80,000,000,000) shall be callable.

3. The authorized capital stock of the Bank may be increased by the Board of Governors by a Super Majority vote as provided in Article 28, at such time and under such terms and conditions as it may deem advisable, including the proportion between paid-in and callable shares.

4. The term "dollar" and the symbol "$" wherever used in this Agreement shall be understood as being the official currency of payment of the United States of America.

### Article 5 Subscription of Shares

1. Each member shall subscribe to shares of the capital stock of the Bank. Each subscription to the original authorized capital stock shall be for paid-in shares and callable shares in the proportion two (2) to eight (8). The initial number of shares available to be subscribed by countries which become members in accordance with Article 58 shall be that set forth in Schedule A.

2. The initial number of shares to be subscribed by countries which are admitted to membership in accordance with paragraph 2 of Article 3 shall be determined by the Board of Governors; provided, however, that no such subscription shall be authorized which would have the effect of reducing the percentage of capital stock held by regional members below seventy-five (75) per cent of the total subscribed capital stock, unless otherwise agreed by the Board of Governors by a Super Majority vote as provided in Article 28.

3. The Board of Governors may, at the request of a member, increase the subscription of such member on such terms and conditions as the Board may determine by a Super Majority vote as provided in Article 28; provided, however, that no such increase in the subscription of any member shall be authorized which would have the effect of reducing the percentage of capital stock held by regional members below seventy-five (75) per cent of the total subscribed capital stock, unless otherwise agreed by the Board of Governors by a Super Majority vote as provided in Article 28.

4. The Board of Governors shall at intervals of not more than five (5) years review the capital stock of the Bank. In case of an increase in the authorized capital stock, each member shall have a reasonable opportunity to subscribe, under such terms and conditions as the Board of Governors shall determine, to a proportion of the increase of stock equivalent to the proportion which its stock theretofore subscribed bears to the total subscribed capital stock immediately prior to such increase. No member shall be obligated to subscribe to any part of an increase of capital stock.

**Article 6 Payment of Subscriptions**

1. Payment of the amount initially subscribed by each Signatory to this Agreement which becomes a member in accordance with Article 58 to the paid-in capital stock of the Bank shall be made in five (5) installments, of twenty (20) per cent each of such amount, except as provided in paragraph 5 of this Article. The first installment shall be paid by each member within thirty (30) days after entry into force of this Agreement, or on or before the date of deposit on its behalf of its instrument of ratification, acceptance or approval in accordance with paragraph 1 of Article 58, whichever is later. The second installment shall become due one (1) year from the entry into force of this Agreement. The remaining three (3) installments shall become due successively one (1) year from the date on which the preceding installment becomes due.

2. Each installment of the payment of initial subscriptions to the original paid-in capital stock shall be paid in dollars or other convertible currency, except as provided in paragraph 5 of this Article. The Bank may at any time convert such payments into dollars. All rights, including voting rights, acquired in respect of paid-in and associated callable shares for which such payments are due but have not been received shall be suspended until full payment is received by the Bank.

3. Payment of the amount subscribed to the callable capital stock of the Bank shall be subject to call only as and when required by the Bank to meet its liabilities. In the event of such a call, payment may be made at the option of the member in dollars or in the currency required to discharge the obligations of the Bank for the purpose of which the call is made. Calls on unpaid subscriptions shall be uniform in percentage on all callable shares.

4. The Bank shall determine the place for any payment under this Article, provided that, until the inaugural meeting of the Board of Governors, the payment of the first installment referred to in paragraph 1 of this Article shall be made to the Government of the People's Republic of China, as Trustee for the Bank.

5. A member considered as a less developed country for purposes of this paragraph may pay its subscription under paragraphs 1 and 2 of this Article, as an alternative, either:

(a) entirely in dollars or other convertible currency in up to ten (10) installments, with each such installment equal to ten (10) percent of the total amount, the first and second installments due as provided in paragraph 1, and the third through tenth installments due on the second and subsequent anniversary dates of the entry into force of this Agreement; or

(b) with a portion in dollars or other convertible currency and a portion of up to fifty (50) per cent of each installment in the currency of the member, following the schedule of installments provided in paragraph 1 of this Article. The following provisions shall apply to payments under this sub-paragraph (b):

(i) The member shall advise the Bank at the time of subscription under paragraph 1 of this Article of the proportion of payments to be made in its own currency.

(ii) Each payment of a member in its own currency under this paragraph 5 shall be in such amount as the Bank determines to be equivalent to the full value in terms of dollars of the portion of the subscription being paid. The initial payment shall be in such amount as the member considers appropriate hereunder but shall be subject to such adjustment, to be effected within ninety (90) days of the date on which such payment was due, as the Bank shall determine to be necessary to constitute the full dollar equivalent of such payment.

(iii) Whenever in the opinion of the Bank, the foreign exchange value of a member's currency has depreciated to a significant extent, that member shall pay to the Bank within a reasonable time an additional amount of its currency required to maintain

the value of all such currency held by the Bank on account of its subscription.

(iv) Whenever in the opinion of the Bank, the foreign exchange value of a member's currency has appreciated to a significant extent, the Bank shall pay to that member within a reasonable time an amount of that currency required to adjust the value of all such currency held by the Bank on account of its subscription.

(v) The Bank may waive its rights to payment under sub-paragraph (iii) and the member may waive its rights to payment under sub-paragraph (iv).

6. The Bank shall accept from any member paying its subscription under sub-paragraph 5 (b) of this Article promissory notes or other obligations issued by the Government of the member, or by the depository designated by such member, in lieu of the amount to be paid in the currency of the member, provided such amount is not required by the Bank for the conduct of its operations. Such notes or obligations shall be non-negotiable, non-interest-bearing, and payable to the Bank at par value upon demand.

**Article 7 Terms of Shares**

1. Shares of stock initially subscribed by members shall be issued at par. Other shares shall be issued at par unless the Board of Governors by a Special Majority vote as provided in Article 28 decides in special circumstances to issue them on other terms.

2. Shares of stock shall not be pledged or encumbered in any manner whatsoever, and they shall be transferable only to the Bank.

3. The liability of the members on shares shall be limited to the unpaid portion of their issue price.

4. No member shall be liable, by reason of its membership, for obligations of the Bank.

**Article 8 Ordinary Resources**

As used in this Agreement, the term "ordinary resources" of the Bank shall include the following:

(i) authorized capital stock of the Bank, including both paid-in and callable shares, subscribed pursuant to Article 5;

(ii) funds raised by the Bank by virtue of powers conferred by paragraph 1 of Article 16, to which the commitment to calls provided for in paragraph 3 of Article 6 is applicable;

(iii) funds received in repayment of loans or guarantees made with the resources indicated in sub-paragraphs (i) and (ii) of this Article or as returns on equity investments and other types of financing approved under sub-paragraph 2 (vi) of Article 11 made with such resources;

(iv) income derived from loans made from the aforementioned funds or from guarantees to which the commitment to calls set forth in paragraph 3 of Article 6 is applicable; and

(v) any other funds or income received by the Bank which do not form part of its Special Funds resources referred to in Article 17 of this Agreement.

## CHAPTER III

## OPERATIONS OF THE BANK

### Article 9 Use of Resources

The resources and facilities of the Bank shall be used exclusively to implement the purpose and functions set forth, respectively, in Articles 1 and 2, and in accordance with sound banking principles.

### Article 10 Ordinary and Special Operations

1. The operations of the Bank shall consist of:

(i) ordinary operations financed from the ordinary resources of the Bank, referred to in Article 8; and

(ii) special operations financed from the Special Funds resources referred to in Article 17.

The two types of operations may separately finance elements of the same project or program.

2. The ordinary resources and the Special Funds resources of the Bank shall at all times and in all respects be held, used, committed, invested or otherwise disposed of entirely separately from each other. The financial statements of the Bank shall show the ordinary operations and special operations separately.

3. The ordinary resources of the Bank shall, under no circumstances, be charged with, or used to discharge, losses or liabilities arising out of special operations or other activities for which Special Funds resources were originally used or committed.

4. Expenses appertaining directly to ordinary operations shall be charged to the ordinary resources of the Bank. Expenses appertaining directly to special operations shall be charged to the Special Funds resources. Any other expenses shall be charged as the Bank shall determine.

**Article 11 Recipients and Methods of Operation**

1. (a) The Bank may provide or facilitate financing to any member, or any agency, instrumentality or political subdivision thereof, or any entity or enterprise operating in the territory of a member, as well as to international or regional agencies or entities concerned with economic development of the region.

(b) The Bank may, in special circumstances, provide assistance to a recipient not listed in sub-paragraph (a) above only if the Board of Governors, by a Super Majority vote as provided in Article 28: (i) shall have determined that such assistance is designed to serve the purpose and come within the functions of the Bank and is in the interest of the Bank's membership; and (ii) shall have specified the types of assistance under paragraph 2 of this Article that may be provided to such recipient.

2. The Bank may carry out its operations in any of the following ways:

(i) by making, co-financing or participating in direct loans;

(ii) by investment of funds in the equity capital of an institution or enterprise;

(iii) by guaranteeing, whether as primary or secondary obligor, in whole or in part, loans for economic development;

(iv) by deploying Special Funds resources in accordance with the agreements determining their use;

(v) by providing technical assistance in accordance with Article 15; or

(vi) through other types of financing as may be determined by the Board of Governors, by a Special Majority vote as provided in Article 28.

**Article 12 Limitations on Ordinary Operations**

1. The total amount outstanding of loans, equity investments, guarantees and other types of financing provided by the Bank in its ordinary operations under sub-paragraphs 2 (i), (ii), (iii) and (vi) of Article 11 shall not at any time be increased, if by such increase the total amount of its unimpaired subscribed capital, reserves and retained earnings included in its ordinary resources would be exceeded. Notwithstanding the provisions of the preceding sentence, the Board of Governors may, by a Super Majority vote as provided in Article 28, determine at any time that, based on the Bank's financial position and financial standing, the limitation under this paragraph may be increased, up to 250% of the Bank's unimpaired subscribed capital, reserves and retained earnings included in its ordinary resources.

2. The amount of the Bank's disbursed equity investments shall not at any time exceed an amount corresponding to its total unimpaired paid-in subscribed capital and general reserves.

**Article 13 Operating Principles**

The operations of the Bank shall be conducted in accordance with the principles set out below.

1. The Bank shall be guided by sound banking principles in its operations.

2. The operations of the Bank shall provide principally for the financing of specific projects or specific investment programs, for equity investment, and for technical assistance in accordance with Article 15.

3. The Bank shall not finance any undertaking in the territory of a member if that member objects to such financing.

4. The Bank shall ensure that each of its operations complies with the Bank's operational and financial policies, including without limitation, policies addressing environmental and social impacts.

5. In considering an application for financing, the Bank shall pay due regard to the ability of the recipient to obtain financing or facilities elsewhere on terms and conditions that the Bank considers reasonable for the recipient, taking into account all pertinent factors.

6. In providing or guaranteeing financing, the Bank shall pay due regard to the prospects that the recipient and guarantor, if any, will be in a position to meet their obligations under the financing contract.

7. In providing or guaranteeing financing, the financial terms, such as rate of interest and other charges and the schedule for repayment of principal shall be such as are, in the opinion of the Bank, appropriate for the financing concerned and the risk to the Bank.

8. The Bank shall place no restriction upon the procurement of goods and services from any country from the proceeds of any financing undertaken in the ordinary or special operations of the Bank.

9. The Bank shall take the necessary measures to ensure that the proceeds of any financing provided, guaranteed or participated in by the Bank are used only for the purposes for which the financing was granted and with due attention to considerations of economy and efficiency.

10. The Bank shall pay due regard to the desirability of avoiding a disproportionate amount of its resources being used for the benefit of any member.

11. The Bank shall seek to maintain reasonable diversification in its investments in equity capital. In its equity investments, the Bank shall not assume responsibility for managing any entity or enterprise in which it has an investment and shall not seek a controlling interest in the entity or enterprise concerned, except where necessary to safeguard the investment of the Bank.

**Article 14 Terms and Conditions for Financing**

1. In the case of loans made or participated in or loans guaranteed by the Bank, the contract shall establish, in conformity with the operating principles set forth in Article 13 and subject to the other provisions of this Agreement, the terms and conditions for the loan or the guarantee concerned. In setting such terms and conditions, the Bank shall take fully into account the need to safeguard its income and financial position.

2. Where the recipient of loans or guarantees of loans is not itself a member, the Bank may, when it deems it advisable, require that the member in whose territory the project concerned is to be carried out, or a public agency or any instrumentality of that member acceptable to the Bank, guarantee the repayment of the principal and the payment of interest and other charges on the loan in accordance with the terms thereof.

3. The amount of any equity investment shall not exceed such percentage of the equity capital of the entity or enterprise concerned as permitted under policies approved by the Board of Directors.

4. The Bank may provide financing in its operations in the currency of the country concerned, in accordance with policies that minimize currency risk.

**Article 15 Technical Assistance**

1. The Bank may provide technical advice and assistance and other similar forms of assistance which serve its purpose and come within its functions.

2. Where expenditures incurred in furnishing such services are not reimbursable, the Bank shall charge such expenditures to the income of the Bank.

## CHAPTER IV

## FINANCES OF THE BANK

**Article 16 General Powers**

In addition to the powers specified elsewhere in this Agreement, the Bank shall have the powers set out below.

1. The Bank may raise funds, through borrowing or other means, in member countries or elsewhere, in accordance with the relevant legal provisions.

2. The Bank may buy and sell securities the Bank has issued or guaranteed or in which it has invested.

3. The Bank may guarantee securities in which it has invested in order to facilitate their sale.

4. The Bank may underwrite, or participate in the underwriting of, securities issued by any entity or enterprise for purposes consistent with the purpose of the Bank.

5. The Bank may invest or deposit funds not needed in its operations.

6. The Bank shall ensure that every security issued or guaranteed by the Bank shall bear on its face a conspicuous statement to the effect that it is not an obligation of any Government, unless it is in fact the obligation of a particular Government, in which case it shall so state.

7. The Bank may establish and administer funds held in trust for other parties, provided such trust funds are designed to serve the purpose and come within the functions of the Bank, under a trust fund framework which shall have been approved by the Board of Governors.

8. The Bank may establish subsidiary entities which are designed to serve the purpose and come within the functions of the Bank, only with the approval of the Board of Governors by a Special Majority vote as provided in Article 28.

9. The Bank may exercise such other powers and establish such rules and regulations as may be necessary or appropriate in furtherance of its purpose and functions, consistent with the provisions of this Agreement.

**Article 17 Special Funds**

1. The Bank may accept Special Funds which are designed to serve the purpose and come within the functions of the Bank; such Special Funds shall be resources of the Bank. The full cost of administering any Special Fund shall be charged to that Special Fund.

2. Special Funds accepted by the Bank may be used on terms and conditions consistent with the purpose and functions of the Bank and with the agreement relating to such Funds.

3. The Bank shall adopt such special rules and regulations as may be required for the establishment, administration and use of each Special Fund. Such rules and regulations shall be consistent with the provisions of this Agreement, except for those provisions expressly applicable only to ordinary operations of the Bank.

4. The term "Special Funds resources" shall refer to the resources of any Special Fund and shall include:

(i) funds accepted by the Bank for inclusion in any Special Fund;

(ii) funds received in respect of loans or guarantees, and the proceeds of any equity investments, financed from the resources of any Special Fund which, under the rules and regulations of the Bank governing that Special Fund, are received by such Special Fund;

(iii) income derived from investment of Special Funds resources; and

(iv) any other resources placed at the disposal of any Special Fund.

**Article 18 Allocation and Distribution of Net Income**

1. The Board of Governors shall determine at least annually what part of the net income of the Bank shall be allocated, after making provision for reserves, to retained earnings or other purposes and what part, if any, shall be distributed to the members. Any such decision on the allocation of the Bank's net income to other purposes shall be taken by a Super Majority vote as provided in Article 28.

2. The distribution referred to in the preceding paragraph shall be made in proportion to the number of shares held by each member, and payments shall be made in such manner and in such currency as the Board of Governors shall determine.

**Article 19 Currencies**

1. Members shall not impose any restrictions on currencies, including the receipt, holding, use or transfer by the Bank or by any recipient from the Bank, for payments in any country.

2. Whenever it shall become necessary under this Agreement to value any currency in terms of another or determine whether any currency is convertible, such valuation or determination shall be made by the Bank.

**Article 20 Methods of Meeting Liabilities of the Bank**

1. In the Bank's ordinary operations, in cases of arrears or default on loans made, participated in, or guaranteed by the Bank, and in cases of losses on equity investment or other types of financing under sub-paragraph 2 (vi) of Article 11, the Bank shall take such action as it deems appropriate. The Bank shall maintain appropriate provisions against possible losses.

2. Losses arising in the Bank's ordinary operations shall be charged:

(i) first, to the provisions referred to in paragraph 1 above;

(ii) second, to net income;

(iii) third, against reserves and retained earnings;

